

Document Produced by deskPDF Unregistered :: http://www.docudesk.com

# ខ្លឹមសារនៃជីវិត

ជីវិតរបស់មនុស្សយើង រមែងតែងតែមាននូវបញ្ហាជារឿយៗ បន្តិចរឿងនេះ បន្តិចរឿងនោះ ដោយច្រើនគឺបញ្ហាតាមផ្លូវចិត្តហ្នឹងឯង បើយើងមិនមានធម៌សម្រាប់ដោះស្រាយទេ វារមែងមានការលំបាកតានតឹងក្នុងចិត្តជាពិតប្រាកដ ហើយវាអាចគ្របសង្កត់ចិត្តបានយូរទៀតផង។

ប្រៀបបីដូចអ្នកបើករថយន្តទៅផ្លូវឆ្ងាយ បើមិនមាននូវគ្រឿងឧបករណ៍សម្រាប់ជួសជុល កែខៃនៅពេលរថយន្តខូច ឬ ធ្លាយកង់ទេនោះ លុះដល់រថយន្តខូច ឬ ធ្លាយកង់ ក៏រមែងមានការលំបាកច្រើនក្នុងដំណើរផ្លូវ ប៉ុន្តែបើយើងមាននូវគ្រឿងបន្លាស់ និង មាននូវឧបករណ៍ផ្សេងៗ ដែលទុកសម្រាប់ប្រើប្រាស់នៅពេលដែលរថយន្តមានបញ្ហាអ្វីណាមួយនោះ យើងក៏កក់ក្ដៅក្នុងចិត្ត ហើយប្រសិនបើរថយន្តមាននូវបញ្ហាពិតមែន ដូចជាធ្លាយកង់



ជាដើម យើងក៏មិនមានទុក្ខលំបាកអ្វីពេកនោះដែរ ព្រោះយើងអាចដោះស្រាយបាន សេចក្ដីនេះយ៉ាងណា ក្នុងជីវិតរបស់យើងម្នាក់ៗ គឺដូចគ្នា បើយើងមិនមាននូវធម៌ជាគ្រឿងសម្រាប់កក់ក្ដៅក្នុងចិត្តទេ ដល់ពេលមានបញ្ហាកើតឡើង ក៏ជាទុក្ខក្រៀមក្រំលំបាកលំបិនក្នុងចិត្តក្រៃលែង។

យើងបានសិក្សាព្រះធម៌ តាមរយៈនៃការអានសៀវភៅ និងតាមរយៈនៃការស្ដាប់ នាំឱ្យកើតការយល់ដឹងក្នុងរឿងពិតទាំងឡាយរបស់ជីវិត យើងក៏បានធូរចិត្តស្រាកស្បើយពីការតានតឹងចង្អៀតចង្អល់ សេចក្ដីកង្វល់ក្នុងបញ្ហាជីវិតពិតជាដោះស្រាយបាន ។

រឿងរ៉ាវផ្សេងៗក្នុងជីវិត ជាវិបត្តិ ជាឧបសគ្គ វានៅតែកើតមានជាធម្មតា ប៉ុន្តែវាមិនមានពិសក្ដៅជ្រាបចូលទៅក្នុងចិត្តឡើយ ព្រោះមានធម៌នៅក្នុងចិត្តរបស់យើងដែលថាមានធម៌ គឺ មានការយល់ដឹងនូវសេចក្ដីពិតរបស់ជីវិត ។

ការសិក្សាព្រះធម៌ វាមានប្រយោជន៍នៅត្រង់ការ

យល់ដឹងនូវសេចក្តីពិតរបស់ជីវិតហ្នឹងឯង ព្រោះមានការយល់ដឹងនេះហើយ ទើបយើងមានសេចក្តីស្ងប់រម្ងាប់ចំពោះមុខនៃឧបសគ្គ ចំពោះមុខនៃវិបត្តិផ្សេងៗក្នុងជីវិត។ ចិត្តស្ងប់រម្ងាប់ធ្វើឱ្យយើងរឹងរឹតតែឆ្លាត តែបើចិត្តខឹងក្រោធវិញ វារមែងធ្វើឱ្យយើងទៅជាមនុស្សល្ងង់មួយរំពេច ។

ពុទ្ធបរិស័ទទាំងឡាយ បានពេញចិត្តក្នុងការសិក្សាស្តាប់នូវព្រះធម៌ជាប្រចាំ ព្រោះបានស្ងប់ចិត្តសមគួរទៅតាមការយល់ដឹង ។ រឹងរឹតតែយល់ដឹង ប្រយោជន៍ គឺសេចក្តីស្ងប់ចិត្តក៏រឹងរឹតតែចម្រើន ដូច្នេះទើបពុទ្ធបរិស័ទមិនធុញទ្រាន់នឹងការក្រេបរសរបស់ព្រះធម៌ឡើយ ។

ពុទ្ធបរិស័ទបានយល់ដឹងអំពីជីវិត គឺ ពុទ្ធបរិស័ទមានការចម្រើនទៅដោយគុណធម៌ ព្រោះគុណធម៌ គឺមេត្តាករុណាក្តី សេចក្តីសន្តោសក្តី សេចក្តីព្យាយាមក្តី សីលក្តីសមាធិក្តី ខន្តីសេចក្តីអត់ធន់ក្តី ជាដើមនេះ រមែងកើតឡើងចម្រើនក្នុងចិត្ត ដោយអាស្រ័យការយល់ដឹងអំពីសេចក្តីពិតរបស់ជីវិតហ្នឹងឯង ។



ដើម្បីជាប្រយោជន៍ធំទូលំទូលាយ សូមពុទ្ធបរិស័ទកុំទៅវត្តតែម្នាក់ឯង កុំសិក្សាស្វែងយល់តែម្នាក់ឯង ត្រូវដឹកនាំ ត្រូវបបួលមិត្តសម្លាញ់ និងអ្នកដទៃផ្សេងទៀត ឱ្យបានចូលមករកផ្លូវត្រូវ ផ្លូវប្រពៃផង គឺជាការជួយសង្គ្រោះមិត្តសម្លាញ់និងអ្នកដទៃផ្សេងទៀតនោះ ដោយការសង្គ្រោះផ្លូវចិត្តផ្លូវវិញ្ញាណ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា **«សព្វទានំ ធម្មទានំ ជិនាតិ»** *ការឱ្យទានធម៌ រមែងឈ្នះការឱ្យទានទាំងពួង* ការឱ្យរបស់ដទៃនោះជារឿងខាងក្រៅ តែការឱ្យនូវព្រះធម៌ជាទាន ជារឿងខាងក្នុង ។ របស់ដទៃជាប្រយោជន៍ដល់រាងកាយ តែព្រះធម៌ជាប្រយោជន៍ដល់ចិត្ត របស់ណាដែលជាប្រយោជន៍ដល់ចិត្ត ជារបស់ដែលយើងគួរឱ្យ គួរចែក ជាចាំបាច់បំផុត ឬថា គួរនាំគេឱ្យមកទទួលដឹងក្នុងរឿងដែលគេគួរយល់ដឹង ឱ្យគេបានដឹង បានយល់ នៅក្នុងគោលធម៌ព្រះពុទ្ធសាសនា ដើម្បីបានដោះស្រាយក្នុងបញ្ហាជីវិតរបស់គេ ។ បើយើងបានឃើញមិត្ត



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

របស់យើងមាននូវសេចក្តីទុក្ខ មាននូវសេចក្តីក្តៅក្រហាយចិត្ត យើងក៏ទៅបបួលគេចូលវត្ត ដូចជាថ្ងៃឧបោសថសីលជាដើម យើងក៏ទៅបបួលគេមក ឱ្យគេបានមកអង្គុយស្ងប់ចិត្តខ្លះ ឱ្យគេបានស្តាប់ បានរៀនដឹងរឿងរបស់ជីវិត ឱ្យគេបានយល់ដឹងការពិត គេក៏បានធូរថយនូវសេចក្តីទុក្ខក្តៅក្រ-ហាយចិត្ត ទៅតាមភាពភ្លឺស្វាងរបស់គេ ។ ការជួយមិត្តសម្លាញ់ក្នុងសភាពបែបនេះ ជាការជួយដ៏ពិតប្រាកដ ជាការជួយយ៉ាងថាវរៈមាំមួន ធ្វើឱ្យមិត្តសម្លាញ់បាននូវវត្ថុដ៏ពិសិដ្ឋឋិតថេរនៅក្នុងចិត្តរបស់គេ អស់កាលជានិច្ចរហូតតទៅ ដូច្នេះការជួយមិត្តភក្តិ តាមផ្លូវព្រះពុទ្ធសាសនា គឺជាការងារដែលគួរធ្វើ ។

ការសាងគុណធម៌ឱ្យចម្រើនក្នុងចិត្តរបស់ខ្លួនផង ជួយឱ្យអ្នកដទៃបាននូវគុណធម៌ប្រចាំចិត្តផង នេះគឺជាប្រយោជន៍ដ៏មានខ្លឹមសារក្នុងជីវិតរបស់មនុស្សយើង ។

**ចប់ខ្លឹមសារនៃជីវិត**



# ខ្លឹមសារនៃសេចក្តីសុខ

មនុស្សចំនួនច្រើនណាស់ ដែលមិនបានសម្លឹងមើលដល់ជីវិតរបស់ខ្លួនឯង មិនបានពិចារណាដល់ខន្ធលោកនេះដែលជាសង្ខារ បានសម្លឹងត្រឹមតែថា យើងនឹងយកការចេះដឹងក្នុងច្បាប់ធម្មជាតិ ដែលមាននៅជុំវិញពិភពលោកមកប្រើ ក្នុងបំណងបំពេញតាមសេចក្តីត្រូវការរបស់ខ្លួនតែប៉ុណ្ណោះ ហើយក៏ស្ទុះទៅក្នុងលោកតាមការចេះដឹងនោះរហូតដល់មានសេចក្តីដឹងខ្លួនថា យើងនេះជាមនុស្សពូកែមានសមត្ថភាពអស្ចារ្យ អាចយកឈ្នះធម្មជាតិបាន ។

មនុស្សលោកយើង ដែលស្ថិតនៅក្នុងសភាពដូចពោលមកនេះឯង បានធ្លាក់ខ្លួនក្លាយទៅជាទាសៈនៃវត្ថុទាំងឡាយ បានយកជីវិតទៅផ្ញើទុកជាមួយនឹងវត្ថុខាងក្រៅបណ្តោយឱ្យសុខទុក្ខរបស់ខ្លួន ស្ថិតនៅក្នុងអំណាចនៃវត្ថុខាងក្រៅនោះៗ ជាគ្រឿងកំណត់ទៅវិញ ខ្លួនឯងមិនជា

Document Produced by deskPDF Unregistered :: http://www.docudesk.com

ឥស្សរៈឡើយ ។ ដោយរវល់តែស្ទុះទៅក្នុងលោក ក៏មិនមានឱកាសបានដឹងថា ជីវិតខ្លួនឯងគឺជាអ្វី មិនធ្លាប់គិត មិនធ្លាប់ពិចារណា នេះបានសេចក្ដីថា នៅមិនទាន់បានយល់ដឹងដល់ច្បាប់ធម្មជាតិតាមពិត គឺធម្មជាតិនៃជីវិតរបស់ខ្លួនឯង នៅមិនទាន់ស្គាល់ឡើយ ។

ព្រះពុទ្ធសាសនាបានទូន្មានឱ្យមានសតិ ទល់គ្នានឹងសេចក្ដីពិតនៃសភាវធម៌ក្នុងជីវិតប្រចាំថ្ងៃ ឱ្យមានបញ្ញាព្រមទទួលយកសេចក្ដីពិត ក្រេបយករសជាតិនៃសេចក្ដីពិតគ្រប់យ៉ាង ។ បើយើងបានអប់រំចិត្តរបស់យើង ឱ្យស្ថិតនៅជាមួយនឹងសេចក្ដីពិតគ្រប់គ្រាគ្រប់វេលាហើយ សេចក្ដីពិតដែលកើតឡើងនោះ វាមិនបានវាយប្រហារមកលើចិត្តរបស់យើងឡើយ តែបើយើងមិនបានអប់រំចិត្ត មិនមានបញ្ញាទទួលយកការពិត នៅពេលមានរឿងអ្វីមួយមកដល់ជីវិត សតិមិនបានកើតឡើងទេនោះ ចិត្តរមែងញាប់ញ័រតក់ស្លុត ហើយសេចក្ដីទុក្ខក៏កើតឡើងមក បៀតបៀនដល់ចិត្តសន្តាន ។



ដោយអាស្រ័យហេតុដូច្នេះ ទើបព្រះពុទ្ធសាសនាបានណែនាំឱ្យយើងមានការអប់រំចិត្ត ដោយការចម្រើនសតិប្បដ្ឋានរលឹកដឹងនូវការពិត ។ កាលបើបានដឹងបានយល់ចូលចិត្តនូវការពិតហើយ ជាទីបំផុត ការដឹងការយល់ចូលចិត្តនូវការពិតនោះឯង រមែងធ្វើឱ្យយើងមានចិត្តសប្បាយ សុខស្ងប់ស្ងាតផូរផង់ក្នុងជីវិតប្រចាំថ្ងៃ ។

អ្វីៗដែលជាសេចក្ដីពិតគឺជាសច្ចៈ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្ដែងចំពោះអាឡវកយក្ខថា « **សច្ចំ ហវេ សាធុតរំ រសានំ** » សច្ចៈហ្នឹងឯង មានរសឆ្ងាញ់ជាងអស់រសទាំងពួង ។

មនុស្សចំនួនច្រើនរមែងមាននូវបញ្ហា ទោះបីថាមាននូវការចេះដឹង អំពីច្បាប់ធម្មជាតិក្រៅខ្លួនយ៉ាងណាក៏ដោយ ការចេះដឹងនោះ វាមានប្រយោជន៍ត្រឹមតែជួយឱ្យគេធ្វើ ឬផលិតអ្វីៗបានច្រើនៗប៉ុណ្ណោះ ប៉ុន្តែការធ្វើ ឬផលិតអ្វីៗបានច្រើនៗនោះ យើងអាចសង្កេតឃើញមានចំណុចមិនល្អផងដែរ ។ ចំណុចមិនល្អម្យ៉ាង គឺការបំពេញ

Document Produced by deskPDF Unregistered :: http://www.docudesk.com

តាមអំណាចនៃកិលេស សេចក្តីប្រាថ្នាការចង់បាន កាលណាបើចេះតែបំពេញទៅតាមអំណាចនៃកិលេសយ៉ាងនេះ កិលេសរមែងធំទៅៗ ម្ល៉ោះហើយ សេចក្តីត្រូវការក៏កាន់តែច្រើនឡើងៗ ធ្វើឱ្យសត្វលោកខ្វះកន្លះជានិច្ច ។ ចំណុចមិនល្អម្យ៉ាងទៀត គឺការដែលចេះតែធ្វើឱ្យមនុស្សលោកស្រួលឡើងៗ តាមរយៈនៃសម្ភារៈទំនើបៗ សេចក្តីរីករាយភ្លើត-ភ្លើនក៏ចេះតែចម្រើន ព្រោះតែប្រាជ្ញាយល់ដឹងព្រមដោយស្មារតីរបស់មនុស្ស មានការលូតលាស់មិនទាន់ឧបករណ៍ប្រើប្រាស់ក្នុងលោក ម្ល៉ោះហើយ វាធ្វើឱ្យមនុស្សលោកស្រវឹងនឹងសម្ភារៈ ក្លាយទៅជាទាសៈនៃវត្ថុទាំងពួង ជ្រៅទៅៗ នឹងធ្វើឱ្យមានការបៀតបៀនគ្នាក៏ច្រើនឡើងៗដែរ។

តាមពិតសេចក្តីត្រេកត្រអាលរបស់សត្វលោកដែលប្រព្រឹត្តទៅក្នុងវត្ថុបំណងផ្សេងៗនោះ គឺវាអាស្រ័យតណ្ហាក្នុងចិត្តហ្នឹងឯង បើយើងមិនយល់ដល់ការពិតនេះទេ យើងចេះតែចង់បានមិនមានទីបំផុតឡើយ ។ សត្វលោករមែងមើលឃើញថា អ្វីៗជាខាងក្រៅនោះ វាល្អ វាសម



ស្អាត ងាយ ស្រួល ។ល។ បានជាភ្លេចគិតថា បើលោភៈតណ្ហាមិនមានក្នុងចិត្តទេ អ្វីៗទាំងអស់ក្នុងលោកមិនជាទីត្រេកត្រអាលឡើយ ហើយបានជាភ្លេចគិតម្យ៉ាងទៀតថាការបំពេញតាមបំណងប្រាថ្នា ធ្វើឱ្យតណ្ហារីតតែធំ ដូច្នេះតើពេលណាទើបខ្លួនឯងលែងត្រូវការចង់បាន បើបានដូចជាមិនបានយ៉ាងនេះ ។

បើមនុស្សយើង បានរលឹកដឹងទាន់ចំពោះការពិតទោះជាការពិតនោះ វាជាអនិដ្ឋារម្មណ៍ គឺមិនគួរជាទីប្រាថ្នាយ៉ាងណាក៏ដោយ ឬថា ជីវិតរបស់ខ្លួនឯងមិនសម្បូរទៅដោយសម្ភារៈផ្សេងៗ ដែលវាជាការពិតម្យ៉ាងនៃជីវិតនោះ ជីវិតរមែងសុខស្ងប់ ហៅថាជីវិតមានសេចក្តីសុខដែលជាឥស្សរៈលើខ្លួនឯង នេះព្រោះហេតុតែបានយល់ដឹងដល់ការពិតនៃជីវិត ដែលជាសង្ខារលោកហ្នឹងឯង ។

ចំពោះមនុស្សដែលរស់នៅដោយបញ្ញា គេអាចចាប់យកចំណុចខ្លឹមសារនៃជីវិត និងចំណុចខ្លឹមសារនៃសេចក្តីសុខបាន ពោលគឺគេមាននូវគុណធម៌ដែលជា

Document Produced by deskPDF Unregistered :: http://www.docudesk.com

ខ្លឹមសារនៃជីវិត និងគេមាននូវសេចក្តីសុខប្រចាំចិត្តសន្តាន ដែលសម្រេចបានមកពីការយល់ដឹងនូវរឿងពិតរបស់ជីវិត គេមិនមែនមានសុខទុក្ខទៅតាមតែការកំណត់ចាត់ចែងអំពីរបស់ខាងក្រៅនោះទេ ។

ចំពោះមនុស្សដែលរស់នៅដោយមិនមានបញ្ញា មិនសិក្សាឱ្យយល់ការពិតរបស់ជីវិត គេមិនអាចចាប់យកខ្លឹមសារនៃសេចក្តីសុខបានឡើយ ថែមទាំងមិនយល់ថាខ្លឹមសារនៃសេចក្តីសុខនោះ ដូចម្តេចផងទេ ម៉្លោះហើយ គេក៏មិនអាចរស់នៅជាសុខដោយបញ្ញាខ្លួនឯងបានដែរ គឺគេត្រូវធ្វើសេចក្តីសុខរបស់ខ្លួនជាមួយនឹងរបស់ខាងក្រៅ។ មុនដំបូងគឺអាស្រ័យនូវបច្ច័យ៤ តាមសេចក្តីត្រូវការរបស់ធម្មជាតិ លុះគេបាននូវសេចក្តីសុខតាមរយៈនៃបច្ច័យ៤ ហើយ គេក៏ក្លាយទៅជាទាសៈនៃវត្ថុខាងក្រៅនោះឯង ។ ដែលថាជាទាសៈ ព្រោះសភាពរបស់ចិត្តមានការក្រវល់-ក្រវាយក្តៅក្រហាយអន្ទះសា ប្រព្រឹត្តទៅរកវត្ថុសម្ភារៈផ្សេងៗ គឺមិនជាឥស្សរៈលើរបស់ទាំងអស់នោះឡើយ ។



មនុស្សដែលមិនមានបញ្ញាក្នុងការរស់នៅ រមែងខ្វះខាតនូវសេចក្តីសុខដែលជាខ្លឹមខាងក្នុង ការបាននូវវត្ថុសម្ភារៈមាននូវអំណោយសុខច្រើនឡើងៗ គឺជាការពង្រីកនូវភាពនៃខ្លួនឯងដែលជាទាសៈ ដូច្នេះវត្ថុសម្ភារៈដែលបានបន្ថែមមកកាន់តែច្រើនឡើងៗនោះ ទើបវាមិនមែនឱ្យតែសេចក្តីសុខប៉ុណ្ណឹងទេ គឺបន្ថែមនូវកិលេសផង បន្ថែមនូវទុក្ខក្នុងភាពជាទាសៈផង ។

សរុបមក សេចក្តីសុខមាន ២ យ៉ាង ÷

**សេចក្តីសុខប្រភេទទី១** គឺជាសេចក្តីសុខជាប់ដោយវត្ថុបម្រុងបម្រើខាងក្រៅ អាស្រ័យវត្ថុនោះៗមកជួយ ។ វត្ថុខាងក្រៅនោះមានច្រើន លោកហៅថា « **អាមិស** » រហូតដល់មនុស្សដែលនៅជុំវិញទាំងអស់ ។ បើមិនមាននូវរបស់ទាំងអស់នេះទេ ក៏មានសេចក្តីដឹងខ្លួនថាខ្វះខាត ហើយក៏កើតទុក្ខ ។ សុខទុក្ខរបស់មនុស្សយើងបែបនេះផ្ញើទុកនឹងរបស់ខាងក្រៅ គឺយើងមិនអាចរស់នៅជាសុខទៅបាន បើមិនមាននូវរបស់ទាំងអស់នេះទេ ។ សេចក្តី

Document Produced by deskPDF Unregistered :: http://www.docudesk.com

សុខនេះមិនបានមាំទាំយឺនយូរឡើយ ព្រោះដោយសារវាជាប់ជាមួយនឹងរបស់ខាងក្រៅហ្នឹងឯង ។ គួរសង្កេតឱ្យឃើញថា នៅពេលខឹងក្តី ភ័យតក់ស្លុតក្តី ទោមនស្សអាក់-អន់ចិត្តក្តី ក្តៅក្រហាយស្តាយក្រោយក្តី និងអ្វីផ្សេងៗទៀតដែលមានលក្ខណៈមិនសប្បាយចិត្ត នៅពេលឃើញ ពេលឮ ជាដើម នេះគឺជាការបញ្ជាក់ដល់សភាពដែលមិនមាននូវខ្លឹមសារនៃសេចក្តីសុខ បណ្តោយឱ្យអស់នូវសេចក្តីសុខរលីងអំពីចិត្តសន្តាន ដូច្នេះទើបពុទ្ធបរិស័ទត្រូវព្យាយាមកំណត់ដឹងនូវសេចក្តីពិតក្នុងពេលនោះៗ ត្រូវឱ្យកើតមាននូវសេចក្តីសុខប្រភេទទី ២ ។

**សេចក្តីសុខប្រភេទទី២** គឺសេចក្តីសុខដែលកើតក្នុងចិត្តរបស់ខ្លួនឯង នៅដក់ក្នុងចិត្តជាប្រចាំ ដោយមិនបានអាស្រ័យរបស់ខាងក្រៅ ដូចជាលាភសក្ការៈ កិត្តិយស កេរ្តិ៍ឈ្មោះ ការគោរពរាប់អាន និងពាក្យសរសើរជាដើមឡើយ ។ សេចក្តីសុខប្រភេទបែបនេះ ជាសេចក្តីសុខមានភាពស្រស់ថ្លា ដែលអាចគ្រប់គ្រងដោយខ្លួនឯងបាន តាម



អំណាចនៃបញ្ញាដ៏ភ្លឺស្វាង ។ ព្រោះអាស្រ័យសេចក្តីសុខប្រភេទទី២នេះ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា « សច្ចៈហ្នឹងឯង មានរសឆ្ងាញ់ជាងអស់រសទាំងពួង »។ សេចក្តីសុខប្រភេទក្រេបយកនូវរសជាតិពីការពិតបែបនេះ មនុស្សភាគច្រើនពុំមានឡើយ ។

មនុស្សយើងនេះ ច្រើនតែសង្ឃឹមចំពោះសេចក្តីសុខចាកវត្ថុខាងក្រៅ ដោយមិនសូវជាបានគិតថា អាត្មា-អញនឹងត្រូវមានពេលវេលារស់នៅតែឯង ដោយវត្ថុទាំង-ឡាយនោះ មិនអាចនឹងនៅស្ថិតស្ថេរជាមួយអាត្មាអញជារៀងរហូតទៅបានឡើយ ។ បើថាបាននៅជាមួយ ក៏វាមិនអាចប្រព្រឹត្តទៅតាមចិត្តប្រាថ្នារបស់យើងដែរ ព្រោះរបស់ទាំងអស់វាស្ថិតនៅក្រោមច្បាប់ធម្មជាតិ វាប្រព្រឹត្តទៅតាមហេតុបច្ច័យរបស់វា ។

នៅក្នុងកងទុក្ខ ១២កង មានទុក្ខម៉្យាងកើតឡើងក្នុងចិត្ត គឺប្រាថ្នារបស់ណាហើយមិនបាននូវរបស់នោះ វារមែងជាទុក្ខតាមកម្លាំងនៃសេចក្តីប្រាថ្នាហ្នឹងឯង ។ ច្បាប់

ធម្មជាតិ គឺការប្រព្រឹត្តទៅតាមហេតុបច្ច័យ ព្រះសម្មា-សម្ពុទ្ធទ្រង់ដាស់តឿនអំពីការពិតនៃធម្មជាតិនេះជារឿយ ៗ ព្រះអង្គបន្ថែមផ្ទួនហើយផ្ទួនទៀត ដើម្បីឱ្យពុទ្ធបរិស័ទបានយល់ បានដឹងនូវសេចក្តីពិតនៃធម្មជាតិដែលជារបស់ធម្មតា ហើយម្យ៉ាងទៀត ព្រះអង្គទ្រង់ទូន្មានឱ្យពុទ្ធបរិស័ទ សមា-ទានកាន់យកនូវសម្មាទិដ្ឋិ ការយល់ត្រូវ ដឹងទាន់នូវហេតុបច្ច័យ ឱ្យជាទីតាំងនៃដំណើរផ្លូវ មិនគប្បីកាន់យកនូវសេចក្តីប្រាថ្នា ការចង់បានដោយតណ្ហា ឱ្យជាទីតាំងនៃដំណើរផ្លូវឡើយ ។

ការបានយល់ដឹងនៅក្នុងហេតុ-បច្ច័យ គឺបានដឹងថាអ្វីៗវាមិនប្រព្រឹត្តទៅតាមការចង់បានរបស់យើងទេ ប៉ុន្តែបើយើងត្រូវការឱ្យវាប្រព្រឹត្តទៅយ៉ាងណា យើងត្រូវដឹងហេតុ-បច្ច័យ ហើយប្រព្រឹត្តធ្វើនូវហេតុបច្ច័យនោះៗ ដើម្បីឱ្យសម្រេចផលយ៉ាងនោះតាមដែលយើងត្រូវការ កុំរវល់តែប្រាថ្នា ឱ្យអ្វីៗប្រព្រឹត្តទៅតាមចិត្តចង់បាន គឺវាប្រព្រឹត្តទៅមិនបានឡើយ ។



បុគ្គលដែលសម្លឹងមើលអ្វីៗទៅតាមហេតុ-បច្ច័យ រមែងមានសេចក្តីស្ងប់ចិត្តផង និងបានជាឥស្សរៈលើខ្លួនឯងច្រើនឡើងផង បណ្តេញនូវតណ្ហាមិនឱ្យចេះតែជាឥស្សរៈលើជីវិតរបស់ខ្លួនឡើយ ។

ជាទីបំផុតនៃជីវិតនេះ ទ្រព្យសម្បត្តិនិងញាតិមិត្តបងប្អូនជួយអ្វីក៏មិនបានដែរ ដូចជាកំពុងឈឺធ្ងន់នៅលើគ្រែសម្រាប់ស្លាប់ រហូតដល់ដៃជើងកម្រើកមិនបាន មាត់និយាយមិនរួច ធ្វើអ្វីក៏មិនបាន អ្នកណាជួយក៏មិនបាន ដាក់អាហារក៏មិនចូល បានត្រឹមតែបន្តក់ទឹកតែប៉ុណ្ណោះ ប៉ុន្តែអ្វីដែលនៅមានហើយអាចធ្វើការបាន គឺចិត្តហ្នឹងឯង ពេលនោះ បើយើងធ្លាប់តែមាននូវសេចក្តីសុខ ដែលអាស្រ័យនឹងអាមិស គឺអ្វីៗនៅខាងក្រៅចិត្តរបស់ខ្លួនប៉ុណ្ណោះ យើងរមែងមាននូវសេចក្តីទុក្ខ សេចក្តីក្តៅក្រហាយតែម្យ៉ាង។ ផ្ទុយមកវិញ បុគ្គលដែលបានហ្វឹកហាត់ចិត្តរបស់ខ្លួនដោយបញ្ញា ដឹងទាន់នូវសភាវៈពិត តាមដូចដែលបានពោលមកហើយនោះ គេអាចធ្វើចិត្តឱ្យមាននូវសេចក្តីស្ងប់គឺ **បស្សទ្ធិ**



Document Produced by deskPDF Unregistered :: http://www.docudesk.com

ដែលជាហេតុជិតរបស់ **សុខៈ** និង **សមាធិ** កាលគេហាត់ចិត្តទុកបានដោយល្អយ៉ាងនេះហើយ ទោះបីគេដេកឈឺម្នាក់ឯងនៅលើគ្រែសម្រាប់ស្លាប់ ដែលអ្វីៗ ឬអ្នកណាៗក៏ជួយមិនបានដែរនោះ គេក៏នៅតែមានសេចក្ដីសុខស្ងប់ក្នុងចិត្តដដែល ។

នេះជាសេចក្ដីសុខដែលជាឥស្សរៈ មានខ្លួនឯងជាទីពឹងចំពោះខ្លួនពិតប្រាកដ ដូច្នេះសូមពុទ្ធសាសនិកជនសិក្សាឱ្យបានជ្រាបច្បាស់ថា ខ្លឹមសារពិតប្រាកដរបស់ជីវិតដែលយើងត្រូវការនោះ គឺជាអ្វី ។ យើងខំសន្សំនូវទ្រព្យសម្បត្តិផ្សេងៗមក ដើម្បីសេចក្ដីសុខ ប៉ុន្តែសេចក្ដីសុខក្នុងពេលជាទីបំផុតនោះគឺនៅត្រង់ចិត្តរបស់យើង ដែលយើងបានហ្វឹកហាត់អប់រំជារឿយៗរាល់ថ្ងៃមក ។ យើងត្រូវអប់រំសន្សំនូវ **បស្សទ្ធិ** គឺសេចក្ដីស្ងប់ ឱ្យជាប្រក្រតីធម្មតាក្នុងជីវិតប្រចាំថ្ងៃ មានជីវិតរស់នៅជាមួយនឹងបញ្ញា ដឹងទាន់សភាវៈពិតបានយ៉ាងសម្បូរ មានសតិសព្វកាល ពិចារណាឃើញខន្ធលោក ដោយនូវសភាពសូន្យទទេចាកខ្លឹមទៀង



ខ្លឹមសុខ និងខ្លឹមខ្លួន សម្រេចបាននូវ **បស្សទ្ធិ** **សុខៈ** និង **សមាធិ** ជាគោលធម៌ប្រចាំជីវិត និងជាសម្បត្តិដ៏មានតម្លៃរបស់យើង ហើយយើងមិនព្រមឱ្យអ្នកណាមកទម្លាយ ធ្វើឱ្យវិនាសបានឡើយ នេះឯងគឺជាខ្លឹមសារដ៏ពិតប្រាកដរបស់ជីវិត ដែលយើងត្រូវការនោះ ។

ពេលដែលយើងបានជួបជាមួយនឹងអ្នកណា យើងក៏បានទទួលនូវអារម្មណ៍ខាងក្រៅចូលមក ពេលខ្លះយើងត្រូវអារម្មណ៍ដែលចូលមកនោះ បោកខ្ទប់ចិត្តរបស់យើង ដូចជា បានឮពាក្យរបស់អ្នកដទៃនិយាយស្ដីបន្ទោសមកដល់យើងជាដើម ដោយយើងខ្វះនូវស្មារតី និងខ្វះការតាំងចិត្តរក្សានូវសម្បត្តិដ៏មានតម្លៃ ធ្វើឱ្យពាក្យសម្ដីរបស់អ្នកដទៃវាយទម្លាយនូវទ្រព្យសម្បត្តិដ៏មានតម្លៃរបស់យើងនោះ ឱ្យវិនាសបាត់បង់ សេចក្ដីរីករាយក្នុងកុសលក្ដី សេចក្ដីសុខស្ងប់ក្ដី ចិត្តនឹងធឹងក្ដី ក៏បានសាបសូន្យអស់អំពីក្នុងចិត្តរលីងពុំមានសល់ឡើយ ។

អនិដ្ឋារម្មណ៍ គឺអារម្មណ៍មិនជាទីប្រាថ្នា នៅក្នុង



Document Produced by deskPDF Unregistered :: http://www.docudesk.com

ជីវិតរបស់យើងម្នាក់ៗ មានច្រើនណាស់ បើយើងមិនមាន ប្រក្រតីចម្រើនសតិទេ យើងមិនអាចនឹងសន្សំនូវសេចក្តីសុខស្ងប់កប់ទុកក្នុងសន្តានចិត្តបានឡើយ ព្រោះហេតុដូច្នេះ ទើបព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង ឱ្យសន្សំនូវសេចក្តីសុខ តាមរយៈនៃការទូន្មានចិត្ត ជាទីបំផុតទ្រង់ត្រាស់ថា ***ការអស់ទៅនៃតណ្ហាឈ្នះអស់ទុក្ខទាំងពួង*** ។

## ចប់ខ្លឹមសារនៃសេចក្តីសុខ

### សៀវភៅសិក្សាជួយដល់អ្នកអាន

សត្វគោក្របីជួយដល់អ្នកស្រែ ភ្លៀងធ្លាក់ត្រូវខែជួយដល់ដំណាំ
រុក្ខជាតិឱ្យផលជួយដល់អ្នកដាំ បើរាំងរាប់ឆ្នាំបានអ្វីពិសា ។
សីលជួយលំអដល់ជនគ្រប់វ័យ សង្ឃមានវិន័យជួយដល់សាសនា
ស្តាប់ធម៌ដោយល្អជួយដល់បញ្ញា សៀវភៅសិក្សាជួយដល់អ្នកអាន ។

ដោយឧបាសក **គុយ-សុធន**



# ខ្លឹមសារនៃសំវេជនីយដ្ឋាន

នៅក្នុងមហាបរិនិព្វានសូត្រ ក្នុងបិដកលេខ ១៦ ទំព័រ ២៩៤ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលអានន្ទ សំវេជនីយដ្ឋាន (ទីកន្លែងដែលគួរឱ្យកើតសង្វេគ) ដែលគួរឃើញដល់កុលបុត្រអ្នកមានសទ្ធានេះមាន ៤កន្លែង ។ សំវេជនីយដ្ឋាន ៤កន្លែង តើដូចម្តេច ។ ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញ របស់កុលបុត្រអ្នកមានសទ្ធា ដោយរលឹកឃើញថា *ព្រះតថាគតប្រសូតក្នុងទីនេះ ដូច្នេះ១* ម្នាលអានន្ទ សំវេជនីយដ្ឋាន ដែលគួរឃើញរបស់កុលបុត្រអ្នកមានសទ្ធា ដោយរលឹកឃើញថា *ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីនេះ ដូច្នេះ១* ម្នាលអានន្ទ សំវេជនីយដ្ឋានដែលគួរឃើញរបស់កុលបុត្រអ្នកមានសទ្ធា ដោយរលឹកឃើញថា *ព្រះតថាគតបានសម្តែងនូវអនុត្តរធម្មចក្កក្នុងទីនេះ ដូច្នេះ១* ម្នាលអានន្ទ



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

សំវេជនីយដ្ឋានដែលគួរឃើញ របស់កុលបុត្រអ្នកមានសទ្ធា ដោយរលឹកឃើញថា *ព្រះតថាគតបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុក្នុងទីនេះ ដូច្នេះ១* ។ ម្នាលអានន្ទ នេះឯង សំវេជនីយដ្ឋានដែលគួរឃើញ ៤កន្លែង របស់កុលបុត្រអ្នកមានសទ្ធា ។

ម្នាលអានន្ទ ពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា អ្នកមានសទ្ធា នឹងមកដោយរលឹកឃើញថា ព្រះតថាគតប្រសូតក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតសម្តែងនូវអនុត្តរធម្មចក្កក្នុងទីនេះ ដូច្នេះក្តី ព្រះតថាគតបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុក្នុងទីនេះ ដូច្នេះក្តី ម្នាលអានន្ទពួកជនណាមួយ នឹងបានដើរមកកាន់ទីចារិកនៃចេតិយ ក៏មានចិត្តជ្រះថ្លា ប្រសិនបើធ្វើមរណកាលបែកធ្លាយរាងកាយទៅ ពួកជនទាំងអស់នោះ ខាងមុខអំពីសេចក្តីស្លាប់ នឹងចូលទៅកាន់សុគតិភព សួគ៌ទេវលោក។

ពុទ្ធបរិស័ទទាំងឡាយ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់



សម្តែងអំពីស្ថានទីសំខាន់ៗ ៤កន្លែង គឺស្ថានទីដែលទ្រង់ប្រសូត១ ទ្រង់ត្រាស់ដឹង១ ទ្រង់សម្តែងនូវធម្មចក្ក១ ទ្រង់បរិនិព្វាន១ ហៅថា *សំវេជនីយដ្ឋាន ៤កន្លែង* ។

**សំវេជ** ក្នុងសេចក្តីដែលថា ជាគ្រឿងរំលឹកដាស់តឿនចិត្តឱ្យកើតសទ្ធានិងបញ្ញា ព្រោះថា កាលបើយើងបានទៅដល់ស្ថានទីដែលហៅថា **សំវេជនីយដ្ឋាន** ៤កន្លែង និងស្ថានទីសំខាន់ៗ ក្នុងព្រះពុទ្ធសាសនាផ្សេងៗទៀតនោះ វត្ថុដែលយើងគួរបាន ដោយសរុបមានពីរយ៉ាងគឺ សទ្ធា និង បញ្ញា ។

ពុទ្ធបរិស័ទខ្លះបានចំពោះតែសទ្ធាប៉ុណ្ណោះ គឺការជ្រះថ្លា និង ជំនឿរឹងរឹតតែមាំទាំខ្លាំងក្លាឡើង ព្រមទាំងកើតបីតិ រំភើបក្នុងចិត្ត ព្រឺរោមព្រឺស្បែក ដែលជាផលសម្រេចបានមកអំពីសទ្ធាហ្នឹងឯង ។ ទោះជាយ៉ាងណាក៏ដោយ កាលបើបាននូវសទ្ធាមាំទាំខ្លាំងក្លាឡើងហើយនោះ ក៏ឈ្មោះថាបានផលហើយ គ្រាន់តែមិនបានពេញលេញបរិបូណ៌ប៉ុណ្ណោះ បើឱ្យបានល្អគ្រប់គ្រាន់នោះគឺបាននូវ

Document Produced by deskPDF Unregistered :: http://www.docudesk.com

បញ្ញាបន្ថែមផង ទើបជាការបានផលពេញលេញបរិបូណ៌។

**បញ្ញាម៉្យាង** គឺការដឹង ការឃើញគតិធម្មតារបស់សង្ខារ បានដល់ការមិនទៀងទាត់ ការទ្រាំមិនបាន និងសភាពសូន្យទទេ។ ជាការយល់ចូលចិត្តនូវសេចក្តីពិតរបស់ធម្មជាតិ ហើយក៏បានបង្អោនយកធម៌មកបដិបត្តិ កម្ចាត់សេចក្តីស្រវឹងក្នុងរឿងផ្សេងៗ បញ្ញានេះជាឧបនិស្ស័យនៃការជាក់ច្បាស់ក្នុងសង្ខារធម៌ ព្រមទាំងញ៉ាំងជីវិតឱ្យរស់នៅដោយសេចក្តីមិនប្រមាទទៀតផង ។

**បញ្ញាម៉្យាងទៀត** គឺបញ្ញានាំមកនូវការនឹករលឹកដល់ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធជាអង្គម្ចាស់ និងនាំឱ្យមានការបដិបត្តិ តាមពាក្យទូន្មានប្រៀនប្រដៅនោះៗ ដោយការទាក់ទងនឹងស្ថានទីនីមួយៗ មានព្រះធម៌ទេសនាផ្សេងៗ ដែលព្រះអង្គទ្រង់បានត្រាស់សម្តែងទុកមក ។

ការបានដោយចំពោះនូវតួបញ្ញា វាអាស្រ័យទៅលើ ***យោនិសោមនសិការ*** គឺការចេះគិត ចេះពិចារណាហ្នឹង-ឯង ដូចជា ការគិតទៅក្នុងរឿងសំវេជនីយដ្ឋាន៤កន្លែង គឺ



កន្លែងទី១ជារឿងទាក់ទងនឹងការប្រសូត បានដល់ការកើត ហើយបន្តទៅជាទីបំផុតគឺកន្លែងទី៤ ជារឿងទាក់ទងនឹងការបរិនិព្វាន បានដល់ការអស់ព្រះជន្ម ដោយមិនមានបដិសន្ធិជាបន្តទៀតឡើយ ។

ចំពោះការប្រសូត និង ការបរិនិព្វាននេះ បើនិយាយអំពីជីវិតនៃព្រះអង្គក្នុងមួយអត្តភាព គឺជារបស់សាមញ្ញដូចគ្រប់គ្នាដែរ បានដល់ ការកើត និងការស្លាប់ ។ អ្នកណាក៏ដោយដែលមានជីវិត គឺរមែងចាប់ផ្តើមពីការកើត ហើយត្រូវមានសេចក្តីស្លាប់ជាទីបំផុត នេះគឺជាគតិធម្មតារបស់ជីវិត មិនមែនមានចំពោះតែព្រះសម្មាសម្ពុទ្ធនោះទេ ប៉ុន្តែ យើងគួរជ្រាបថា ព្រះពុទ្ធជាអង្គម្ចាស់ មានបន្ថែមនូវសេចក្តីសំខាន់ពីរយ៉ាង នៅក្នុងរវាងការប្រសូតនិងការបរិនិព្វានរបស់ព្រះអង្គ ពីរយ៉ាងនោះបានដល់ *ការត្រាស់ដឹង១ និង ការសម្តែងនូវបឋមទេសនា១* នេះឯងជាផ្នែកសំខាន់និងពិសេស ដែលធ្វើឱ្យព្រះជន្មឬជីវិតរបស់ព្រះអង្គមានភាពប្រសើរជាងជីវិតនៃសត្វទាំងឡាយ ។

Document Produced by deskPDF Unregistered :: http://www.docudesk.com

ការត្រាស់ដឹងនោះ បើយើងសម្លឹងមើលឱ្យចំលើអត្ថន័យសំខាន់ ក៏គឺការដែលព្រះពុទ្ធជាអង្គម្ចាស់ទ្រង់បានសម្រេចនូវទិសដៅ ដែលព្រះអង្គទ្រង់បំណងប្រាថ្នាអស់កាលដ៏យូរអង្វែងមកហើយហ្នឹងឯង នេះជាការសម្រេចនូវប្រយោជន៍ផ្ទាល់ព្រះអង្គ ធ្វើព្រះជន្មជីពរបស់ព្រះអង្គឱ្យប្រសើរខ្ពង់ខ្ពស់ជាទីបំផុត ដោយរកបុគ្គលណាប្រៀបឱ្យស្មើពុំបានឡើយ ។

ជាបន្តមក ការសម្តែងបឋមទេសនា គឺជាការបំពេញនូវប្រយោជន៍ដើម្បីអ្នកដទៃ ដោយសេចក្តីថា ព្រះ-អង្គទ្រង់ប្រោសសត្វលោក ញុំាងសត្វលោកឱ្យបានសម្រេចនូវប្រយោជន៍ តាមសមគួរដល់ឧបនិស្ស័យ ។

ប្រយោជន៍ទាំងពីរប្រការ បើពោលជាភាសាបាលីគឺ **អត្តទត្ថ** និង **បរទត្ថ** ។ ការត្រាស់ដឹងនោះ ជាការសម្រេចដ៏យ៉ាងពេញលេញនូវ **អត្តទត្ថ** ឬ **អត្តហិត** បានដល់ប្រយោជន៍ខ្លួន ចំណែកការសម្តែងនូវបឋមទេសនា ជាការចាប់ផ្តើមនៃការបំពេញ **បរទត្ថ** ឬ **បរហិត** បាន



ដល់ប្រយោជន៍ដើម្បីអ្នកដទៃ ។

គោលធម៌ពីរយ៉ាងនេះ ជាខ្លឹមសារដ៏សំខាន់នៅក្នុងការបដិបត្តិធម៌របស់ពុទ្ធបរិស័ទយើង ព្រះពុទ្ធជាអង្គម្ចាស់ទ្រង់ត្រាស់សម្តែងជារឿយៗ ឱ្យពុទ្ធបរិស័ទបំពេញនូវប្រយោជន៍សម្រាប់ខ្លួនឯង និងប្រយោជន៍សម្រាប់អ្នកដទៃ ។ ប្រយោជន៍ទាំងពីរយ៉ាងនេះជាប់ទាក់ទងគ្នា គឺថាបុគ្គលដែលអាចនឹងបំពេញនូវប្រយោជន៍ ឱ្យដល់អ្នកដទៃបានយ៉ាងល្អនោះ ត្រូវតែកសាងខ្លួន ញុំាងប្រយោជន៍របស់ខ្លួនឱ្យបានចម្រើនជាមុនសិន ។ ទូន្មានអ្នកដទៃផង តម្កល់ខ្លួនដោយប្រពៃដើម្បីជាគំរូផង បើយើងរឹតតែបានសម្រេចនូវប្រយោជន៍ខ្លួនឯងច្រើនប៉ុនណា យើងក៏រឹតតែញុំាងប្រយោជន៍ឱ្យដល់អ្នកដទៃបានសម្រេចច្រើនប៉ុណ្ណោះដែរ។

ប្រយោជន៍ខ្លួនឯង គឺខ្លួនឯងមានសតិបញ្ញា មានភាពក្លៀវក្លា មានការអង់អាច មានសេចក្តីសុខ មានជីវិតស្ងប់រម្ងាប់ ។ ប្រយោជន៍ខ្លួនឯងនេះ គឺជាទីតាំងដ៏មាំក្នុងការបំពេញប្រយោជន៍ឱ្យដល់អ្នកដទៃទៀត ព្រោះហេតុ

នេះ ទើបមានទូវគុណសម្បត្តិរបស់ព្រះអរហន្តដែលថា ជាបុគ្គលបានសម្រេចនូវប្រយោជន៍របស់ខ្លួនហើយ រហូតដល់មិនមានកិច្ចអ្វីដើម្បីខ្លួនឯងទៀតឡើយ ពោលគឺមានសីលសមាធិបញ្ញាបរិបូណ៌ហើយ ឯសេចក្តីសុខស្ងប់ ភាពជាឥស្សរៈលើតណ្ហា ក៏ត្រូវបានសម្រេចពេញលេញគ្រប់គ្រាន់ទាំងអស់ផងដែរ។កាលបើមាននូវសេចក្តីចម្រើនដល់ព្រមក្នុងខ្លួនយ៉ាងនេះហើយ ក៏នាំយកនូវសេចក្តីចម្រើនទាំងនោះ មានសេចក្តីសុខស្ងប់ជាដើម ទៅផ្សព្វផ្សាយចែកចាយឱ្យដល់អ្នកដទៃផង ដោយមេត្តាករុណាតទៅ ។

ស្ថានទីដែលព្រះពុទ្ធជាអង្គម្ចាស់ត្រាស់ដឹង និងស្ថានទីប្រកាសនូវបឋមទេសនា គឺជាស្ថានទីសម្រាប់ឱ្យពុទ្ធបរិស័ទនឹករលឹកដល់ប្រយោជន៍ទាំងពីរយ៉ាង ដូចបានសម្តែងបញ្ជាក់រួចហើយ ។ ស្ថានទីដែលទ្រង់ប្រសូត១ ស្ថានទីដែលព្រះពុទ្ធជាអង្គម្ចាស់ត្រាស់ដឹង១ និង ស្ថានទីដែលព្រះអង្គទ្រង់បរិនិព្វាន១ គឺជាស្ថានទីដែលធ្វើឱ្យយើងនឹកឃើញដល់ថ្ងៃ១៥កើតខែពិសាខ ព្រោះថ្ងៃ ១៥កើត



ខែ ពិសាខ គឺជាថ្ងៃព្រះអង្គទ្រង់ប្រសូត ទ្រង់ត្រាស់ដឹង និងទ្រង់បរិនិព្វាន ។

មានថ្ងៃសំខាន់មួយទៀតខាងផ្លូវព្រះពុទ្ធសាសនា គឺថ្ងៃ១៥កើតខែអាសាឍ ដែលជាថ្ងៃព្រះអង្គទ្រង់សម្តែងនូវបឋមទេសនា។ នៅថ្ងៃ១៥កើតខែអាសាឍនេះ ពុទ្ធបរិស័ទយើងគួរតែនាំគ្នាប្រារព្ធធ្វើនូវពិធីគោរពបូជា ឱ្យបានឱឡារិក គគ្រឹកគគ្រេង ដូចវិសាខបូជា ឬមាឃបូជាដែរ បើបានដូចនេះ ពុទ្ធបរិស័ទយើងត្រូវមានថ្ងៃបូជាមួយទៀត គឺ **អាសាឡ្ហបូជា** (បូជានៅក្នុងថ្ងៃ ១៥កើត ខែអាសាឍ)។

ថ្ងៃ១៥កើតខែអាសាឍបន្ទាប់ពីការត្រាស់ដឹង គឺជាថ្ងៃដែលយើងត្រូវនឹករលឹកឃើញ ដល់ការចាប់ផ្តើមប្រោសសត្វលោក របស់ព្រះសម្មាសម្ពុទ្ធ ។ ការនឹករលឹកឃើញយ៉ាងនេះ រមែងធ្វើឱ្យពុទ្ធបរិស័ទយើង តាំងចិត្តអធិដ្ឋានកសាងខ្លួនឱ្យបានមាំទាំ និងតាំងចិត្តជួយអ្នកដទៃឱ្យបាននូវប្រយោជន៍ យ៉ាងហោចណាស់ក៏មិនបានគិតបៀតបៀនអ្នកដទៃដែរ ។



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ក្នុងដំណើរជីវិតរបស់ព្រះសម្មាសម្ពុទ្ធ យើងឃើញកិច្ចសំខាន់ៗនៅក្នុងថ្ងៃ១៥កើតខែអាសាឍ ក្រៅអំពីការត្រាស់សម្ដែងបឋមទេសនានោះ មាន៤ទៀតគឺ ÷

១-ព្រះអង្គទ្រង់យាងចុះចាប់បដិសន្ធិ

២-ព្រះអង្គទ្រង់យាងចេញទៅបួស

៣-ព្រះអង្គទ្រង់ចាប់ផ្ដើមឱ្យមានព្រះសង្ឃ

៤-ព្រះអង្គទ្រង់សម្ដែងយមកប្បាដិហារិយ៍ ។

ដូច្នេះ រួមទៅជា៥មុខ ដែលជាកិច្ចសំខាន់ៗនៅក្នុងថ្ងៃ១៥កើតខែអាសាឍ ។

ជាបន្តទៅទៀតនេះ យើងនឹងបានន្ទូវបញ្ហាចាកការពិចារណា អំពីរូបកាយ និងធម្មកាយ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូតនៅក្នុងព្រៃលុម្ពិនី គឺជាការប្រាកដឡើងនៃព្រះរូបកាយរបស់ព្រះអង្គ ។ ព្រះរូបកាយរបស់ព្រះអង្គដែលជាព្រះសិទ្ធត្ថនេះ មានសេចក្ដីសំខាន់ដ៏យ៉ាងក្រៃលែងព្រោះថា ដោយអាស្រ័យនូវព្រះរូបកាយនេះឯង ទើបភាពជាព្រះសម្មាសម្ពុទ្ធអាចកើតឡើងបាន ។ កាលព្រះសិទ្ធត្ថ



ទ្រង់បំពេញនូវសេចក្ដីព្យាយាម ក៏អាស្រ័យព្រះរូបកាយនេះឯងដែរបំពេញនូវសេចក្ដីព្យាយាមនោះ ហើយបន្តពីការព្យាយាមទៅ ក៏បានអាស្រ័យនូវព្រះរូបកាយហ្នឹងឯងទៀត ក្នុងការទទួលនូវព្រះសព្វញ្ញុតញ្ញាណ ត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ បានសេចក្ដីថា ទ្រង់អាស្រ័យនូវព្រះរូប-កាយនេះ ទើបអាចញ៉ាំងនូវព្រះ ***ធម្មកាយ*** ឱ្យប្រាកដឡើងបាន ។

ធម្មកាយរបស់ព្រះអង្គ បានប្រាកដឡើងនៅក្រោមដើមព្រះមហាពោធិ៍នៅពុទ្ធគយា នុ៎ះគឺជាការត្រាស់ដឹង ដូច្នេះ សំវេជនីយដ្ឋានទី១ ជាទីប្រាកដឡើងនៃព្រះរូបកាយឯចំណែក សំវេជនីយដ្ឋានទី២ ស្ថានទីត្រាស់ដឹង គឺជាទីប្រាកដឡើងនៃព្រះធម្មកាយ ។

***ធម្មកាយ*** ក៏គឺជំនុំ ឬកងនៃធម៌ ។ កាលដែលព្រះពុទ្ធជាអង្គម្ចាស់ទ្រង់អាស្រ័យនូវព្រះរូបកាយ បានញ៉ាំងនូវព្រះធម្មកាយឱ្យប្រាកដ គឺជាចំណែកនៃប្រយោជន៍របស់ព្រះអង្គ ហើយបន្តទៅទៀតនោះ ព្រះអង្គទ្រង់បានយាង

Document Produced by deskPDF Unregistered :: http://www.docudesk.com

ទៅកាន់ទីចារិក ញាំងព្រៃឥសិបតនមិគទាយវ័ន ដែលជាសំវេជនីយដ្ឋានទី៣ ឱ្យបានជាកន្លែងចាប់ផ្តើមប្រកាសផ្សព្វផ្សាយនូវព្រះធម្មកាយ ។

***សំវេជនីយដ្ឋានទី៣នេះ*** ព្រះអង្គទ្រង់បានប្រកាសផ្សព្វផ្សាយនូវព្រះធម្មកាយរបស់ព្រះអង្គ ឱ្យកើតឡើងដល់អ្នកដទៃផង ដោយមានបុគ្គលជាបន្ទាល់សាក្សីមុនដំបូង គឺ ព្រះអញ្ញាកោណ្ឌញ្ញៈ អ្នកបាននូវធម្មចក្ខុភ្នែកឃើញធម៌ ។

ព្រះអញ្ញាកោណ្ឌញ្ញៈជាមនុស្សបាននូវព្រះធម្មកាយ (ពោធិបក្ខិយធម៌៣៧ប្រការ ) មុនដំបូងបង្អស់បន្ទាប់អំពីព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ ហើយបានឧបសម្បទាជាឯហិភិក្ខុមុនគេទៀត នៅក្នុងថ្ងៃបានសម្រេចព្រះធម្មកាយហ្នឹងឯង គឺថ្ងៃ១៥កើត ពេញបូណ៌មី ខែអាសាឍ ដែលជាថ្ងៃ **កំណើតព្រះសង្ឃ** ។

ព្រះសម្មាសម្ពុទ្ធ បានធ្វើព្រះធម្មកាយឱ្យប្រាកដឡើងក្នុងលោក ដោយការផ្សព្វផ្សាយចេញទៅកាន់អ្នកដទៃ ។ កាលព្រះធម្មកាយបានប្រាកដក្នុងលោកហើយ និង



ព្រះរូបកាយបានបំពេញកិច្ចយ៉ាងបរិបូណ៌ហើយ ព្រះរូបកាយនោះ ក៏បានទៅដល់ទីបំផុតនៅឯសំវេជនីយដ្ឋានទី៤ គឺស្ថានទីបរិនិព្វានក្នុងនគរកុសិនារា ។

ព្រះរូបកាយ បានធ្វើកិច្ចឱ្យព្រះធម្មកាយប្រាកដដល់សត្វលោកហើយ ព្រះរូបកាយក៏រលត់ទៅ បែកធ្លាយទៅ ចោលព្រះធម្មកាយ (ពោធិបក្ខិយធម៌ )ទុកឱ្យជាប្រយោជន៍ដល់សត្វលោកតទៅ ។ ព្រះធម្មកាយនេះពុំទាន់បានសាបសូន្យអស់ទៅ តាមព្រះរូបកាយនោះឡើយ នេះឯងជាការទំនាក់ទំនងរវាងព្រះរូបកាយ និង ព្រះធម្មកាយ ។

គួរចាំទុកថា ក្នុង៤ស្ថាននោះ ផ្តើមដំបូងព្រះរូបកាយប្រាកដ នៅនាទីប្រសូត ។ ដោយអាស្រ័យនូវព្រះរូបកាយ ព្រះធម្មកាយក៏បានប្រាកដឡើង នៅនាព្រះពោធិព្រឹក្សពុទ្ធគយាស្ថានទីត្រាស់ដឹង ហើយក៏ធ្វើនូវព្រះធម្មកាយនោះ ឱ្យសុសសាយខ្ចរខ្ចាយផ្សាយជាទូទៅ ដើម្បីជាប្រយោជន៍ដល់សត្វលោក នៅព្រៃឥសិបតនមិគទាយវ័ន ។ កាលបានបំពេញកិច្ចនាទីចប់សព្វគ្រប់ហើយ ព្រះរូបកាយ

ក៏បានបែកធ្លាយនៅនានគរកុសិនារា បានចាកចោល ព្រះធម្មកាយទុកឱ្យស្ថិតនៅរហូតតមក ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា «បុគ្គលណាឃើញតថាគត បុគ្គលនោះឃើញធម៌ បុគ្គលណាឃើញធម៌ បុគ្គលនោះឃើញតថាគត » ការឃើញធម៌ គឺឃើញការពិតនៃជីវិត (បដិច្ចសមុប្បាទធម៌ ) អ្នកដែលបានឃើញធម៌ដោយបញ្ញាចក្ខុ គឺជាអ្នកមាននូវចំណែកនៃព្រះធម្មកាយដូច្នេះ ទើបអ្នកឃើញធម៌ក៏រមែងបានឃើញនូវព្រះសម្មាសម្ពុទ្ធដោយពិតដែរ គឺជាការឃើញដោយញាណចក្ខុ ។

សូម្បីក្នុងសម័យកាលដែលព្រះអង្គគង់ព្រះជន្មនៅឡើយក៏ដោយ អ្នកដែលឃើញព្រះសម្មាសម្ពុទ្ធដោយពិត គឺត្រូវឃើញដោយញាណចក្ខុតែប៉ុណ្ណោះ ព្រោះមំសចក្ខុ (ភ្នែកសាច់ធម្មតានៃសត្វលោកទាំងពួង ) ឃើញបានត្រឹមតែរូបារម្មណ៍គឺពណ៌របស់រូបកាយប៉ុណ្ណឹងឯង មិនអាចឃើញនូវព្រះធម្មកាយបានឡើយ ។

ព្រះធម្មកាយជាភាសាបាលី ប្រែថា កង ឬទីជំនុំ



ទីប្រជុំរួមនៃព្រះធម៌ ចំណែករូបកាយ គឺជាទីប្រជុំ ឬកងនៃរូបធម៌ ពោលគឺ ដី ទឹក ភ្លើង ខ្យល់ មកប្រជុំគ្នាយ៉ាងមានរបៀប ដោយអំណាចការចាត់ចែងរបស់កម្ម ចិត្ត ឧតុ និងអាហារ ទើបបានកើតជារូបកាយឡើង ។

ព្រះធម្មកាយ គឺជាព្រះធម៌ដែលជាធម្មតារបស់ធម្មជាតិ ប៉ុន្តែ ព្រះធម៌បានកើតមកដើម្បីជាប្រយោជន៍ដល់សត្វលោក កាលបើមានការប្រជុំគ្នានូវព្រះធម៌ទាំងនោះហើយ ដោយអាស្រ័យការយល់ចូលចិត្ត និងការប្រព្រឹត្តបដិបត្តិ ។ កាលបើយើងយល់ចូលចិត្តចំពោះព្រះធម៌ដោយបញ្ញាហើយ ព្រះធម៌ក៏បានមកជាកាយរបស់យើងផងដែរ តែជានាមកាយ ដោយឡែកអំពីរូបកាយ ។

កាលដែលមានគុណធម៌ សេចក្ដីល្អ មកប្រកបគ្នាបន្តិចម្ដងៗ យើងក៏នឹងមាននូវជំនុំ ឬកងនៃព្រះធម៌កើតក្នុងខ្លួនយើងច្រើនឡើងៗដែរ បើយើងប្រព្រឹត្តបដិបត្តិតាមគោលរបស់មេត្តា យើងក៏មាននូវមេត្តាចូលមកដើម្បីធ្វើការប្រជុំ យើងបំពេញនូវករុណា ករុណាក៏ចូលមក យើង



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

បំពេញនូវមុទិតា និងឧបេក្ខា មុទិតានិងឧបេក្ខាក៏ចូលមក ឬបើយើងបំពេញនូវឥន្ទ្រិយ យើងមានសទ្ធាជាអង្គមួយ យើងមានវីរិយៈជាអង្គមួយ យើងមានសតិជាអង្គមួយ យើងមានសមាធិជាអង្គមួយ យើងមានបញ្ញាជាអង្គមួយ អង្គធម៌ទាំងអស់ក៏ចូលមករួមប្រជុំជាព្រះធម្មកាយ ព្រះធម្មកាយក៏ប្រាកដច្រើនឡើងៗជាលំដាប់ រហូតបានជាព្រះធម្មកាយដ៏មាំទាំ គឺលោកុត្តរធម៌ ។

ព្រះធម្មកាយនេះមិនមានរូបរាង ព្រោះបើជារូបរាង គឺជារូបកាយ រីឯរូបកាយនោះក៏បានពោលហើយថាជាទីប្រជុំនៃរូបធម៌ ចំណែកព្រះធម្មកាយនេះជាទីប្រជុំនៃនាមធម៌ ។ ព្រះធម្មកាយគឺជានាមធម៌សុទ្ធ ព្រោះហេតុនេះ ព្រះធម្មកាយគឺជានាមកាយហ្នឹងឯង ប៉ុន្តែ នាមកាយជាសព្ទទូលំទូលាយ អាចជាកុសលក៏បាន អាចជាអកុសលក៏បាន និងអាចជាអព្យាក្រឹតក៏បាន ។

ព្រះធម្មកាយ ចាប់ផ្ដើមដោយកុសលធម៌ មកប្រជុំគ្នាច្រើនឡើងៗ ជាទីបំផុត ក៏បានទៅជាលោកុត្តរកុសល



រួចហើយក៏បានតាំងនៅជាអព្យាក្រឹត ស្ថិតក្នុងហឫទ័យនៃព្រះអរហន្ត ។ ព្រះធម្មកាយមានកិច្ចកម្ចាត់កម្ចាយនូវពួកធម៌ជាអកុសលឱ្យរលត់អស់អំពីសន្តាន ទើបបានស្ថិតជាអព្យាក្រឹតក្នុងជីវិតរបស់ព្រះសម្មាសម្ពុទ្ធ ដូច្នេះ ការផ្សព្វផ្សាយនូវព្រះធម្មកាយ គឺត្រូវផ្សព្វផ្សាយតាមរយៈនៃព្រះធម៌ទេសនារបស់ព្រះអង្គ ។

ពុទ្ធបរិស័ទ ត្រូវធ្វើការយល់ចូលចិត្តឱ្យបានច្បាស់អំពីព្រះធម្មកាយ កុំយល់ច្រឡំថាព្រះធម្មកាយមានរូបរាងយ៉ាងនេះ ឬយ៉ាងនោះ ។ សេចក្ដីនេះលើកយកមកអធិប្បាយ ដោយអាស្រ័យមានទំនាក់ទំនងគ្នាជាមួយនឹងខ្លឹមសារនៃសំវេជនីយដ្ឋាន៤កន្លែង ដូចដែលបានពោលមកហើយ ។

ការស្វែងរកនូវប្រយោជន៍ ដោយការពិចារណាស្វែងយល់អំពីអត្ថន័យខ្លឹមសារនៃសំវេជនីយដ្ឋាន បានច្រើនប៉ុនណាៗ គឺអាស្រ័យនៅលើយោនិសោមនសិការហ្នឹងឯង ដូចបានបញ្ជាក់ពីខាងដើមហើយ និង ទាំងអស់

ប្រមូលមក ប្រយោជន៍ដែលសម្រេចបានពីសំវេជនីយដ្ឋាន បានដល់ សទ្ធា និង បញ្ញា ។

ពុទ្ធបរិស័ទគ្រប់ព្រះអង្គគ្រប់គ្នា រមែងបាននូវប្រយោជន៍អំពីសំវេជនីយដ្ឋាន៤កន្លែង បាននូវគតិធម៌សម្រាប់នាំយកមកពិចារណា និងប្រព្រឹត្តបដិបត្តិ ដើម្បីឱ្យកើតផលល្អដល់ជីវិតរបស់ខ្លួនច្រើនឡើងៗ គឺវាស្ថិតនៅលើឧបនិស្ស័យរបស់ពុទ្ធបរិស័ទ គ្រប់ព្រះអង្គគ្រប់គ្នាហ្នឹងឯង ។

**ចប់ខ្លឹមសារនៃសំវេជនីយដ្ឋាន**

≈✵≈✵≈✵≈

**សុរិយាចន្ទ្រា និងព្រះធម្មា**

| | |
|---|---|
| សុរិយាបំភ្លឺត្រឹមតែពេលថ្ងៃ | ចន្ទពេញបូណ៌មីបំភ្លឺពេលយប់ |
| រីឯព្រះធម៌សែនល្អលើសលប់ | បំភ្លឺថ្ងៃយប់ឥតបង់រស្មី ។ |
| បំភ្លឺដល់ជនដែលប្រព្រឹត្តល្អ | គោរពព្រះធម៌សន្សំបារមី |
| រក្សាកិត្តិយសរស់នៅមានន័យ | ទោះចាប់ភពថ្មីក៏មិនងងឹត ។ |

ដោយឧបាសក **គុយ-សុធន**



# ខ្លឹមសារនៃការបួស

ការចេញចាកផ្ទះចូលកាន់ផ្នួសបួសជាបព្វជិត នៅក្នុងព្រះពុទ្ធសាសនា គឺដោយអាស្រ័យសទ្ធានិងឆន្ទៈក្នុងការប្រព្រឹត្តបដិបត្តិ តាមពាក្យប្រៀនប្រដៅរបស់ព្រះ-ពុទ្ធជាអង្គម្ចាស់ មានបំណងសិក្សាអប់រំនៅក្នុងព្រះធម៌វិន័យ នេះជាឧបនិស្ស័យដ៏ប្រពៃខ្ពង់ខ្ពស់ ឈានចូលទៅរកខ្លឹមសារនៃការបួស ។

ដើម្បីឱ្យការបួសបានសម្រេចនូវប្រយោជន៍ យ៉ាងពិតប្រាកដនោះ ត្រូវតែយល់ឱ្យច្បាស់អំពីខ្លឹមសារនៃការបួស សូម្បីតែពាក្យថា «ការបួស» ឬពាក្យថា «បព្វជ្ជា» ក៏ត្រូវតែយល់ដឹង ។

បព្វជ្ជា ឬការបួសនេះ តាមការសំគាល់ជាទូទៅ គឺមានមកជាយូរយារហើយ តាំងតែមុនព្រះពុទ្ធសាសនាកើតឡើងម៉្លេះ ។ នៅក្នុងពពួកមនុស្សទាំងឡាយ មាន



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

មនុស្សខ្លះចេះគិតពិចារណា សម្លឹងឃើញជីវិតរបស់មនុស្សទាំងឡាយនៅក្នុងសង្គម មានការប្រព្រឹត្តទាំងល្អ ទាំងអាក្រក់ ពេលខ្លះសង្គមក៏មានសេចក្តីចម្រើន ពេលខ្លះក៏មានការសាបសូន្យ និងផ្លាស់ប្តូរប្រែប្រួលទៅជាប្រការផ្សេងៗ មិនមានការទៀងទាត់ពិតប្រាកដ រកសារៈនិងសេចក្តីសុខឱ្យឋិតថេរពុំបានឡើយ ។

ការមានជីវិតរស់នៅកណ្តាលនៃសង្គម ក្រៅអំពីសេចក្តីក្រវល់ក្រវាយ និងក្រៅអំពីរកសេចក្តីសុខចាកការស្ងប់បានដោយលំបាកហើយនោះ វានៅមានសភាពមិនប្រសើរម្យ៉ាងទៀត គឺការមិនងាយមានឱកាសក្នុងការស្វែងរកសេចក្តីពិតនៃជីវិត មិនងាយនឹងដុសខាត់សម្អាតចិត្តឱ្យផុតចាកពីការសៅហ្មង ព្រោះហេតុដូច្នេះ ទើបមានមនុស្សខ្លះចេញចាកអំពីសង្គមមនុស្ស ហើយទៅនៅក្នុងទីឆ្ងាយ ដើម្បីឱ្យមានសេចក្តីសុខស្ងប់ និងមានពេលគិតពិចារណាស្រាវជ្រាវរាវរកសេចក្តីពិត ដោយមិនមានការរំខានអំពីរឿងកង្វល់ផ្សេងៗ ដែលទាក់ទងជាមួយមនុស្ស



ដទៃទៀត ។

ដោយការដកខ្លួន ចេញអំពីសង្គមមនុស្សហ្នឹងឯង ទើបមានការកើតឡើងនូវបព្វជ្ជាគឺការបួស មានការមិនគ្រប់គ្រងផ្ទះ រស់នៅក្នុងព្រៃធំ និងទីស្ងាត់ផ្សេងៗទៀត មានគុហាភ្នំជាដើម រហូតដល់រកឃើញផ្លូវនៃសេចក្តីសុខស្ងប់ ចូលកាន់ឈានសមាបត្តិ ស្ងប់ចាកកាមរាគៈ មិនក្រវល់ក្រវាយនៅក្នុងរឿងរបស់មនុស្សលោកឡើយ ។

ការស្វែងរកទីពឹង និងខ្លឹមសាររបស់ជីវិត ព្រមដោយសេចក្តីសុខស្ងប់ក្នុងចិត្តយ៉ាងនេះ បានមានមកជាលំដាប់ និងមានជាសក្ខីភាពបញ្ជាក់អំពីភាពជាឥស្សរៈលើកាមតណ្ហា និងបញ្ជាក់ប្រាប់អំពីមាគ៌ា ដែលត្រូវចេញចាកអំពីជរា ព្យាធិ និងមរណៈ រហូតដល់សម័យព្រះសិទ្ធត្ថបរមពោធិសត្វ ព្រះអង្គទ្រង់ប្រសូតនៅព្រៃលុម្ពិនី ។

មុនដំបូង ព្រះសិទ្ធត្ថក៏ស្ថិតនៅនាកណ្តាលហ្វូងនៃពពួកជន កណ្តាលកាមគុណក្នុងព្រះបរមរាជវាំងដែរ និងមាន ការខ្វល់ខ្វាយ ជាមួយនឹងរឿងស្វែងរកសេចក្តីសុខ

Document Produced by deskPDF Unregistered :: http://www.docudesk.com

អំពីវត្ថុទាំងឡាយ ដែលហៅថាកាមសុខហ្នឹងឯង ក្នុងនោះ ព្រះបាទសិរីសុទ្ធោទនៈ ជាព្រះបិតា បានចាត់ចែងនូវវត្ថុកាមគុណដ៏ប្រណីតសម្រាប់ទាក់ចិត្តព្រះអង្គផងដែរ ។

ក្រោយមក ព្រះសិទ្ធត្ថទ្រង់បានឃើញថា ការដែលនឹងនៅតាមៗគ្នា កើតមកហើយក៏ចាស់ ហើយក៏ឈឺស្លាប់ទៅតាមគ្នា វិលវល់ចុះឡើងដូចនេះ វាជាការដែលគួរឱ្យរង្កៀសណាស់ រកខ្លឹមសារអ្វីមិនមានឡើយ ។ ក្នុងទីបំផុត ព្រះសិទ្ធត្ថបរមពោធិសត្វ ទ្រង់បានពិចារណារកផ្លូវថា ធ្វើយ៉ាងណាទើបអាចរកឃើញសេចក្តីពិតនៃជីវិត នឹងបានរួចផុតចាកចាស់ឈឺស្លាប់ ។

ការមានជីវិតរស់នៅកណ្តាលសេចក្តីខ្វាយខ្វល់ ក្នុងសង្គមនោះ មិនមានអំណោយឱកាសឡើយ ព្រោះជីវិតគ្រប់គ្រងផ្ទះ មានការហួងហែងកង្វល់ស្មុគស្មាញ មានរឿងរ៉ាវរួបរឹតជុំជិតខ្លួន « **សម្ពាធោ ឃរាវាសោ** ជីវិតគ្រប់គ្រងផ្ទះមានសភាព ចង្អៀត » ។

ទ្រង់បានឃើញថា ការចេញទៅបួស ដូចយ៉ាង



អ្នកបួសដែលមានក្នុងសម័យនោះឯង គឺជាអ្នកបួសបន្តគ្នាតាំងតែអំពីសម័យបុរាណកាលដ៏យូរលង់មក ជាផ្លូវចេញដ៏ល្អ « **អព្ភោកាសោ បព្វជ្ជា** ការបួសគឺជាការចេញទៅកាន់ទីវាលស្រឡះដ៏ក្រៃលែង មានសេរីភាព ទៅកាន់ទីណាក៏បាន » ទើបទ្រង់សម្រេចព្រះទ័យ លះបង់សភាពនៃជីវិតក្នុងព្រះបរមរាជវាំង ហើយស្តេចចេញបួសបំពេញនូវនេក្ខម្មបារមីជាចុងក្រោយ ។ ព្រះអង្គទ្រង់ស្វែងរកការចេះដឹង អំពីសំណាក់អ្នកបួសផ្សេងៗ និងទ្រង់ប្រព្រឹត្តបដិបត្តិតាមផ្លូវរបស់អ្នកបួសទាំងនោះ គ្រប់បែបយ៉ាង ។

ព្រះអង្គទ្រង់យាងទៅសាកល្បង តាមផ្លូវបដិបត្តិរបស់អ្នកបួសក្នុងសម័យនោះ ជាទីបំផុតទ្រង់បានជ្រាបថា លទ្ធិរបស់អ្នកបួសទាំងអស់នោះ ព្រមទាំងឫសី តាបសផ្សេងៗ មិនមែនជាផ្លូវដែលនឹងនាំឱ្យបានសម្រេចនូវការចេះដឹងដ៏ខ្ពង់ខ្ពស់ ដើម្បីផុតចាកអំពីជរាមរណៈឡើយ ទើបព្រះអង្គស្វែងរកផ្លូវដោយព្រះអង្គឯងផ្ទាល់ ហើយព្រះអង្គក៏បានត្រាស់ដឹងនៅថ្ងៃ១៥កើតពេញបូណ៌មីខែពិសាខ មុន

Document Produced by deskPDF Unregistered :: http://www.docudesk.com

ព្រះអង្គបរិនិព្វាន៤៥ឆ្នាំ ក្នុងព្រះជន្មព្រះអង្គ៣៥ព្រះវស្សា។

កាលដែលព្រះអង្គបានត្រាស់ដឹងហើយ ទ្រង់ក៏បាននាំយកនូវព្រះធម៌មកផ្សព្វផ្សាយ ទូន្មានប្រៀនប្រដៅដល់សត្វលោក ។ អ្នកដែលមានសទ្ធាព្រមដោយឧបនិស្ស័យជាមួយនឹងព្រះអង្គ បានយល់អំពីជីវិតពិត ហើយបានយល់ចូលចិត្តអំពីគោលនៃសេចក្ដីល្អផ្សេងៗ ដែលសម្រាប់ញ៉ាំងជីវិតឱ្យបានដល់នូវសេចក្ដីសុខ សេចក្ដីចម្រើន ក៏បានមកសូមប្រព្រឹត្តបដិបត្តិជាមួយព្រះអង្គ ដោយការលះបង់នូវផ្ទះសម្បែង ឈប់នៅគ្រប់គ្រងផ្ទះ ដែលហៅថាចេញបួសហ្នឹងឯង ។

ការបួសគឺ **បព្វជ្ជា** នេះ ប្រែយកសេចក្ដីងាយៗ ថាការវៀរចាកនូវបាបអកុសលផ្សេងៗដោយទូទៅ ។ គឺជាការហ្វឹកហាត់អប់រំខ្លួនឯង ព្រោះថាអកុសលមិនមែនជារបស់ដែលងាយក្នុងការលះបង់នោះទេ ពេលខ្លះលះបានតែខាងក្រៅ ប៉ុន្តែនៅខ្វល់ខាងក្នុង លះបានផ្លូវកាយផ្លូវវាចាហើយ តែកិលេសនៅប្រជុំគ្នាក្នុងចិត្ត របៀបដូច



សត្រូវប្រមូលកម្លាំងទ័ព ដូច្នេះក្នុងការធ្វើសង្គ្រាមជាមួយសត្រូវគឺកិលេស ត្រូវមានការហ្វឹកហាត់អប់រំទូន្មានខ្លួនដ៏យ៉ាងហ្មត់ចត់ក្រៃលែង ។ ការបួសនេះទើបជាការហ្វឹក-ហាត់អប់រំខ្លួនឱ្យបានហ្មត់ចត់ បរិសុទ្ធស្អាត ជាការសិក្សាព្យាយាម ដុសខាត់កម្ចាត់កិលេសគ្រឿងសៅហ្មងចិត្ត និងសេចក្ដីអាក្រក់ផ្សេងៗឱ្យខ្ជាត់បាត់អស់ទៅ ។

កិលេសតួសំខាន់ដែលប្រាកដច្បាស់ គឺការឃើញតែពីខ្លួនឯង ដែលធ្វើឱ្យមនុស្សស្វែងរកតែគ្រឿងសេពសោយដើម្បីយកមកផ្គាប់ផ្គុនខ្មោចកិលេសក្នុងខ្លួនហ្នឹងឯង ។សត្វលោករីករាយវង្វេងវង្វាន់នៅក្នុងកាមគុណ នាំគ្នាពោលសរសើរកាមនិងអាមិសផ្សេងៗ ហើយសម្លុតគំរាមកំហែងអ្នកដទៃ ប្រព្រឹត្តអំពើបៀតបៀនអ្នកដទៃ ដោយអាងគ្នីគ្នា អាងខ្នង អាងអញ ដែលសុទ្ធតែជាការអាងខុសទាំងអស់ ព្រោះថា កំហុសដែលខ្លួនបានប្រព្រឹត្តទាំងប៉ុន្មាននោះ វាធ្វើឱ្យយើងក្លាយជាមនុស្សអាក្រក់ស្រេចទៅហើយ ។

បព្វជ្ជាគឺការបួស មានន័យសេចក្ដីថា ការបញ្ចៀស

ខ្លួនឱ្យបានរួចផុត អំពីការបៀតបៀនអ្នកដទៃ ពោលគឺការគេចចេញអំពីអំពើអាក្រក់របស់ខ្លួនឯង និងការដកខ្លួនចេញឱ្យផុតអំពីកាម បានដល់កិលេសកាមក្នុងចិត្តផង វត្ថុកាមសម្ភារបែបផ្សេងៗផង ។

បព្វជ្ជា គឺការលះបង់នូវគ្រឿងហ្មងហែង គ្រឿងកង្វល់ជាខាងក្រៅ មានទ្រព្យសម្បត្តិ មាសប្រាក់ ព្រមទាំងអ្វីៗទាំងអស់ផ្សេងទៀត ដែលជាគ្រឿងនាំឱ្យជាប់ជំពាក់ទៅណាមិនរួច ។

ជីវិតរបស់អ្នកបួស ព្រះសម្មាសម្ពុទ្ធទ្រង់ប្រៀបទៅនឹងបក្សី ដែលមានតែស្លាបមួយគូ នឹងទៅណា ពេលណាក៏រមែងទៅបានពេលនោះ ប៉ុន្តែ បើអ្នកបួសមានភារៈអ្វីផ្សេងៗ មានកិច្ចការរបស់សង្ឃជាដើម ដូចយ៉ាងសម័យបច្ចុប្បន្ននេះ មានការគ្រប់គ្រងក្រុម ពួកគណៈ គ្រប់គ្រងអាវាស និងមានការគ្រប់គ្រងធំដុំលើសពីនេះទៅទៀតនោះ ក៏ឃើញថា មិនងាយទៅណាមកណាចោលការគ្រប់គ្រងបានឡើយ ដូច្នេះទើបត្រូវមានសតិដាស់តឿនខ្លួន



ជារឿយៗរាល់ថ្ងៃថា «ឧត្តមគតិនៃជីវិតរបស់អ្នកបួសនោះគឺសំដៅទៅរកភាពជាឥស្សរៈ ភាពវាលស្រឡះ មិនជំពាក់ទាក់ទិនក្នុងរបស់ផ្សេងៗ ដើម្បីមានឱកាសបំពេញកិច្ចការរបស់សមណៈ បានយ៉ាងបរិបូណ៌ » ។

បានបួសហើយ មិនមែនចប់ស្រេចត្រឹមតែបានបួសប៉ុណ្ណោះ រួចហើយនៅស្ងៀមៗ ហាក់ដូចជាគ្មានការអ្វីធ្វើនោះឡើយ ពិតមែនតែបួសហើយឈប់រវល់នឹងការងាររបស់អ្នកគ្រប់គ្រងផ្ទះ ប៉ុន្តែការដកខ្លួនចេញពីការងារគ្រប់-គ្រងផ្ទះនោះ គឺដើម្បីបានឱកាសបំពេញការងាររបស់អ្នកបួស ដែលជាការងារដ៏ក្តៅគគុកក្នុងសមរភូមិ បានដល់ការធ្វើសង្គ្រាមច្បាំងជាមួយនឹងខ្លួនឯង « មិនមានការតស៊ូណា ឱ្យខ្លាំងក្លាជាងការតស៊ូដើម្បីឈ្នះចិត្តរបស់ខ្លួនឯងឡើយ » ។ ការបួសគ្រាន់តែជាការចាប់ផ្តើមប៉ុណ្ណោះ នឹងត្រូវព្យាយាមបដិបត្តិជាបន្ត ដើម្បីបានសម្រេចផលដែលជាទិសដៅនៃការបួសនោះឯង ។ ការដែលនឹងបានសម្រេចផលពីបព្វជ្ជា ត្រូវតែមានការ « រៀន » គឺ



Document Produced by deskPDF Unregistered :: http://www.docudesk.com

សិក្សាហ្វឹកហាត់ ញុំាងជីវិតរបស់ខ្លួនឱ្យចម្រើនទៅដោយគុណធម៌ អប់រំកាយ វាចា ចិត្ត ឱ្យបានល្អ ឱ្យបានប្រណីត ឱ្យបានចម្រើនរុងរឿងជាភិយ្យោភាព រហូតដល់លះបង់នូវបាបអកុសលបានអស់ ជាការរួចផុតអំពីកិលេស និងជាការបានឈ្នះនូវកងទុក្ខទាំងពួង ។

មានពាក្យថា « បួសរៀន » បានសេចក្តីថា បួសដើម្បីរៀន ឬថា ការបួសក៏គឺជីវិតនៃការរៀនដឹង សិក្សាហ្វឹកហាត់ឱ្យជីវិតចម្រើនទៅដោយប្រាជ្ញាស្មារតី ដូច្នេះ ពាក្យថា « រៀន » ត្រូវគ្នានឹងពាក្យបាលីថា «សិក្ខា » ។

សារៈសំខាន់នៃការបួសទាំងអស់ គឺស្ថិតនៅត្រង់ការសិក្សាអប់រំ ដែលភាសាក្នុងព្រះពុទ្ធសាសនាហៅថា សិក្ខាហ្នឹងឯង ។

ប្រទេសខ្មែរយើង ជាប្រទេសកាន់ព្រះពុទ្ធសាសនា ដូច្នេះ តាំងពីដើមមកខ្មែរយើងបានឃើញប្រយោជន៍នៃការបួស ទើបបានគិតថា បើមិនអាចបួសបានរហូតទេក៏ដោយចុះ គឺគ្រាន់តែបានបួស ២-៣ វស្សាក៏ជាប្រយោជន៍



ដែរ ដើម្បីបានឱកាសដុសខាត់ចិត្ត ធ្វើឱ្យជីវិតចម្រើនទៅដោយការចេះដឹង រួចហើយទើបលាសិក្ខាមកទទួលខុសត្រូវក្នុងសង្គមគ្រួសារ និង សង្គមជាតិវិញ ។

ទិសដៅនៃការបួស គឺការរួចផុតចាកទុក្ខ ដូចបានរៀបរាប់ពីខាងដើមច្រើនហើយ ប៉ុន្តែដូចនៅប្រទេសខ្មែរយើង បានមានប្រពៃណីមួយរបស់ប្រជាជនខ្មែរ គឺថា បើកុលបុត្រមានឱកាស ត្រូវឱ្យបានបួសក្នុងមួយរយៈវេលាយូរឬឆាប់តាមសមគួរដល់អធ្យាស្រ័យ ដើម្បីនឹងបានសិក្សាអប់រំ តាមគោលព្រះពុទ្ធសាសនាផង ដើម្បីបានជាឧប-និស្សយសម្បត្តិដ៏ប្រសើរឧត្តមផង ។

សម័យបច្ចុប្បន្ននេះ ការបួសក្នុងប្រទេសខ្មែរយើង មានទិសដៅច្រើនប្រការផ្សេងទៀត អាចសរុបបានជា ៣ ទិសដៅ ចំពោះទិសដៅដែលល្អប្រពៃ ក្រៅអំពីបួសដើម្បីរួចផុតចាកទុក្ខនោះគឺ:

**-ទិសដៅប្រការទី១-** *ជាការបំពេញតួនាទីរបស់ពុទ្ធសាសនិកជន* ដោយសេចក្តីថា ពុទ្ធសាសនិកជន



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

មានបំណងចង់ជួយព្រះពុទ្ធសាសនា ដោយការរក្សាព្រះធម៌វិន័យឱ្យបានមាំទាំ ព្រោះថា បើព្រះពុទ្ធសាសនាគឺពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ តាំងនៅពុំទាន់សាបសូន្យទេ ក៏នឹងបានជាប្រយោជន៍ដល់មនុស្សទាំង-ឡាយ ជួយឱ្យមនុស្សទាំងឡាយមានជីវិតល្អប្រពៃ និង ជួយឱ្យសង្គមជាតិមាននូវមូលប់ត្រជាក់ ពោលគឺម្លប់សាសនាហ្នឹងឯង ។

វិធីដែលល្អជាទីបំផុត ក្នុងការរក្សាព្រះពុទ្ធសាសនាបានដល់ការចូលទៅបួសរៀនព្រះធម៌វិន័យ និង រក្សាទុកនូវពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះអង្គ ដែលបានរៀនចេះចាំមក ដោយការប្រព្រឹត្តបដិបត្តិខ្លួនឯងផង ដឹកនាំឱ្យអ្នកដទៃបដិបត្តិផង របៀបនេះហៅថា « **មន្តអាយុព្រះពុទ្ធសាសនា** » ។

ក្រៃលែងជាងនេះទៅទៀត កាលបើរៀនដឹងហើយប្រព្រឹត្តបដិបត្តិតាម មានដំណើរជីវិតទៅតាមធម៌ ក៏ស្មើនឹងយកព្រះពុទ្ធសាសនា មកទុកក្នុងជីវិតរបស់យើងដែរ



ឬថា យកខ្លួនយើងជាទីរក្សាព្រះពុទ្ធសាសនា បើធ្វើបានយ៉ាងនេះ ជីវិតអ្នកទ្រទ្រង់វិន័យគឺជាអាយុជីវិតរបស់ព្រះ-វិន័យ ជីវិតអ្នកទ្រទ្រង់ធម៌គឺជាអាយុជីវិតរបស់ព្រះធម៌ដរាបណា ដែលនៅមានជីវិតនៃពុទ្ធបរិស័ទ ដរាបនោះព្រះពុទ្ធសាសនារមែងគង់វង្ស យ៉ាងនេះឯងដែលហៅថា *ការបួសជាការបំពេញតួនាទីរបស់ពុទ្ធសាសនិកជន* ។

**-ទិសដៅប្រការទី២-** *ជាការបំពេញតួនាទីរបស់ខ្លួនជាជនជាតិខ្មែរ* ដោយសេចក្ដីថា ព្រះពុទ្ធសាសនាចូលមកក្នុងប្រទេសខ្មែរ ហើយក៏បានទៅជាមរតករបស់ជនជាតិខ្មែរ ។ ជនជាតិខ្មែរយើងបានឃើញថា ព្រះពុទ្ធ-សាសនា ជាទ្រព្យសម្បត្តិដែលមានតម្លៃដ៏ខ្ពង់ខ្ពស់បំផុតនៃប្រទេសជាតិ និងសង្គមរបស់យើង ព្រោះថា កាលដែលព្រះពុទ្ធសាសនាចូលមកហើយ ក៏មានគោលនៃការអប់រំធ្វើឱ្យមនុស្សប្រព្រឹត្តល្អ បើមានមនុស្សល្អច្រើនឡើងៗ ការបៀតបៀនគ្នាក្នុងសង្គមក៏ត្រូវបានថយចុះជាលំដាប់ ។ ព្រះពុទ្ធសាសនា បានជួយឱ្យមនុស្សសន្ទឹកសន្ទាប់ក្លាយជា

Document Produced by deskPDF Unregistered :: http://www.docudesk.com

មនុស្សល្អរស់នៅក្នុងសង្គម ។ ក្រៅអំពីជួយក្នុងផ្នែកគុណធម៌អប់រំឱ្យមនុស្សល្អ គឺល្អទាំងការប្រព្រឹត្ត ល្អទាំងផ្លូវចិត្តហើយ ក៏នៅមានប្រយោជន៍ ដែលជាឫសគល់នៃវឌ្ឍនធម៌របស់ជាតិយើងទៀតផង សូម្បីតែភាសារបស់យើងក៏បានមកអំពីភាសាបាលី រហូតដល់ភាសាសំស្ក្រឹតសន្ធឹកសន្ធាប់ សិល្ប៍សាស្ត្រផ្សេងៗ ក៏បានមកអំពីវត្តអារាម និង អ្វីៗផ្សេងទៀត ដែលមានការរីកចម្រើននៅក្នុងសង្គមជាតិយើងនេះ គឺបានមកអំពីព្រះពុទ្ធសាសនា ជាឫសគល់ច្រើនជាទីបំផុត ។

ដោយអាស្រ័យហេតុផលដូចបានពោលមកនេះ យើងបានឃើញថា ព្រះពុទ្ធសាសនាជាសម្បត្តិប្រចាំជាតិរបស់យើង គួរខ្មែរយើងជួយគ្នាដើម្បីរក្សាឱ្យមានជាបន្តទៅ ។ ការបួសនេះឯង ជាការជួយរក្សាព្រះពុទ្ធសាសនាដែលជាទ្រព្យសម្បត្តិរបស់ជាតិ ដូច្នេះយើងក៏បានយល់ព្រមឱ្យខ្មែរមានឱកាសបានមកបួស នឹងបានជួយគ្នារក្សាទ្រព្យសម្បត្តិរបស់ជាតិខ្មែរ ឱ្យបានឋិតថេរយឺនយូរតទៅ



នេះឯងជាទិសដៅប្រការទី២នៃការបួស គឺការបំពេញតួនាទីរបស់ខ្លួនជាជនជាតិខ្មែរ ។

**-ទិសដៅប្រការទី៣-** *ជាការតបស្នងដល់ព្រះគុណរបស់មាតាបិតា* ដូចដែលយើងបានកាន់យកជាប្រពៃណីមកថា បើអ្នកណាបានបំបួសកូនហើយ ក៏បានបុណ្យបានកុសលច្រើនណាស់ កូនបានមកបួសហើយ ជាការជួយឱ្យឪពុកម្តាយបានតោងជាយសំពត់កាសាវៈ ទៅកាន់ស្ថានសួគ៌ រហូតដល់បានជាញាតិព្រះសម្មាសម្ពុទ្ធទៀតផង ដូច្នេះ ការបួសនេះក៏បានមកជាទិសដៅមួយ គឺដើម្បីតបស្នងសងគុណដល់មាតាបិតា ។

ការបួសតបស្នងសងគុណមាតាបិតានេះ បើសម្លឹងមើលឱ្យជ្រៅទៅ ក៏ជារឿងពិតរបស់ចិត្ត ព្រោះថា តាមធម្មតារបស់មាតាបិតារមែងស្រឡាញ់កូន ហើយជាទីបំផុតនៃសេចក្តីស្រឡាញ់របស់មាតាបិតា គឺស្រឡាញ់កូនហ្នឹងឯង កាលបើស្រឡាញ់កូនយ៉ាងនេះ ក៏រមែងចង់ឱ្យកូនបានល្អ ចង់ឱ្យកូនបានសេចក្តីសុខ បើកូនបានល្អប្រកបព្រម

Document Produced by deskPDF Unregistered :: http://www.docudesk.com

ដោយសេចក្តីសុខហើយ មាតាបិតាក៏បានសេចក្តីសុខដែរ។ ដូច្នេះទើបមានពាក្យពោលថា « កតញ្ញូតាធម៌របស់បុត្រធីតា ជាសេចក្តីសុខរបស់មាតាបិតា » ផ្ទុយមកវិញ បើកូនមិនល្អ មិនមាននូវសេចក្តីសុខទេ ឪពុកម្តាយក៏មាននូវសេចក្តីទុក្ខ ហើយទុក្ខរបស់ឪពុកម្តាយព្រោះកូននេះ ក៏ជាទុក្ខខ្លាំងក្លា ជាទុក្ខដ៏ធំធេង ។

មាតាបិតាប្រាថ្នាល្អចំពោះកូន ទើបគិតថា ធ្វើយ៉ាងណាដើម្បីឱ្យកូនបានល្អហើយមាននូវសេចក្តីសុខ ។

ការដែលកូនបានល្អមាននូវសេចក្តីសុខទៅបាន គឺកូនត្រូវមានការសិក្សា មានការហ្វឹកហាត់អប់រំយ៉ាងល្អ ។ មិនចំពោះតែក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ មាតាបិតានៅនឹកគិតប្រាថ្នាចង់ឱ្យកូនបានល្អមាននូវសេចក្តីសុខ ក្នុងអនាគតរបស់កូនទៀតផង ព្រោះថា តទៅកាលខាងមុខឪពុកម្តាយនឹងមិនបាននៅជាមួយកូនរហូតតទៅឡើយ ហើយកូននឹងទៅជាយ៉ាងណាៗនោះ ឪពុកម្តាយក៏គិតកង្វល់ក្នុងរឿងអនាគតរបស់កូនថា តើបន្តទៅខាងមុខ កូននឹងជាមនុស្ស



ល្អ មានសេចក្តីសុខ មានសេចក្តីសម្រេច មានជីវិតរស់នៅក្នុងសង្គមលោកបានល្អឬទេ នឹងរក្សាវង្សត្រកូលបានឬទេ ជាការគិតសព្វសារពើ នេះឯងជាកង្វល់របស់មាតាបិតាទាំងឡាយ រួមសេចក្តីមកថា សេចក្តីប្រាថ្នាចង់ឱ្យកូនបានជាមនុស្សល្អមាននូវសេចក្តីសុខនេះ ស្ថិតក្នុងចិត្តរបស់មាតាបិតាគ្រប់គ្រា គ្រប់វេលា ។

ព្រះពុទ្ធសាសនាបានជួយឱ្យមានការសិក្សាអប់រំ ជាពិសេសគឺយុវវ័យ ព្រោះថាជាធម្មតារបស់យុវវ័យ រមែងចូលចិត្តដើរកំសាន្តទៅនេះទៅនោះ និង មានការសេព-គប់នូវមិត្តសម្លាញ់ផ្សេងៗដ៏ច្រើន ។ ជារៀងរាល់ថ្ងៃ ឪពុកម្តាយរមែងមានការហួងហែងកូន ដោយចំពោះគឺកូនប្រុសដែលតែងតែខិលខូច មិនស្តាប់បង្គាប់តាមពាក្យទូន្មាន ។ កាលដែលកូនទៅណាមកណា ឪពុកម្តាយមានចិត្តព្រួយខ្វល់ខ្វាយ ដោយគិតថា ក្រែងកូននឹងទៅមានរឿងជាមួយអ្នកណា តើកូនបានធ្វើត្រឹមត្រូវដែរឬទេ ជាការគិតកង្វល់ចុះឡើង រហូតទាល់តែកូនត្រឡប់មកដល់ផ្ទះវិញ ហើយ

ដឹងថាគ្មានរឿងអ្វីទេ ទើបបានធូរចិត្តខ្លះ ។

មាតាបិតាតែងនឹកគិតថា តើត្រូវធ្វើយ៉ាងណា ទើបអាចធានាបានថា កូននឹងជាមនុស្សល្អ អាចទទួលខុសត្រូវក្នុងជីវិតខ្លួនឯងបាន អាចទទួលខុសត្រូវលើក្រុមគ្រួសារបាន និង អាចទទួលខុសត្រូវក្នុងសង្គមជាតិបាន ។

កាលកូនបានបួសជាព្រះសង្ឃនៅក្នុងវត្ត គ្រងសំពត់ពណ៌លឿងហើយ មានវិន័យ មានសីលល្អបរិសុទ្ធត្រឹមត្រូវ ( *ដោយគ្រាន់តែបានបួសប៉ុណ្ណឹង* ) មាតាបិតាក៏សប្បាយចិត្ត ព្រោះមិនបានកង្វល់ហួងហែង ។ សប្បាយចិត្តព្រោះបានកូនចូលទៅក្នុងឧត្តមភេទ ចិត្តមាតាបិតាស្ងប់មិនក្រវល់ក្រវាយ នឹកសប្បាយត្រង់ដែលកូនបានបួស បានរៀនសូត្រចេះដឹងក្នុងព្រះធម៌ ព្រះវិន័យ ។

មិនមែនត្រឹមតែប៉ុណ្ណោះទេ មាតាបិតានៅមានសេចក្ដីរីករាយសប្បាយចិត្តក្នុងរឿងផ្សេងទៀត ដោយសង្ឃឹមថា កាលបើកូនបានបួស បានសិក្សាអប់រំតាមព្រះធម៌វិន័យដូច្នេះហើយ តទៅមុខកូននឹងបានជាបព្វជិតល្អ



ឬមនុស្សល្អ ម្យ៉ាងទៀត ជាប្រក្រតីរបស់មាតាបិតា គឺតែងតែរវល់ជាមួយកិច្ចការងារចិញ្ចឹមជីវិត ពេលខ្លះក៏មិនមានឱកាសបានចូលវត្តផងដែរ មិនមានពេលសូម្បីតែនឹកតាមផ្លូវចិត្ត ព្រោះថារវល់នឹកគិតដល់រឿងផ្សេងៗទៀត ប៉ុន្តែដល់ទៅកូនបានបួសហើយ នឹកដល់កូនពេលណា ក៏នឹកដល់ព្រះសង្ឃពេលនោះដែរ កាលនឹកដល់ព្រះសង្ឃ ក៏នឹកដល់វត្ត នឹកដល់ព្រះសាសនា សេចក្ដីនេះបានន័យថា កូនបានជួយនាំចិត្ត បង្អោនចិត្តរបស់មាតាបិតា ឱ្យចូលមកកាន់ព្រះសាសនា ឱ្យចូលមកកាន់ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ គឺឱ្យចូលមករកព្រះធម៌ ។

ការដែលកូនបានចូលមកបួសជាបព្វជិតល្អត្រឹមត្រូវ ក៏ជាការជួយឱ្យមាតាបិតា អញ្ជើញមកកាន់ព្រះសាសនាផងដែរ ចាប់ផ្ដើមតាំងអំពីធ្វើឱ្យចិត្តមាតាបិតាទន់ទោរមករកវត្ត រហូតដល់មានឱកាសបានអញ្ជើញមកវត្តច្រើនឡើងៗ ។ ពេលនឹកលោកកូន ត្រូវមកវត្ត ដល់ក្នុងវត្តជួបព្រះសង្ឃ ធ្វើចង្ហាន់ប្រគេនលោកកូន ត្រូវប្រគេនព្រះសង្ឃ



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

ក្នុងវត្តច្រើនអង្គទៀតផង ។ អញ្ជើញមកវត្តញឹកញាប់ បានស្តាប់ព្រះធម៌ក៏ច្រើន បានរៀនព្រះធម៌ផង បំរើព្រះសង្ឃផង នេះឯងទើបជាផ្លូវដែលជួយឱ្យមាតាបិតា បានចូលជិតព្រះពុទ្ធសាសនា ហៅថា *ជាញាតិរបស់ព្រះសម្មាសម្ពុទ្ធយ៉ាងពិតប្រាកដ* ។

កូនដែលមានការយល់ដឹងបានល្អ ពេលមកបួសហើយ ខ្លួនឯងបានឃើញគុណតម្លៃរបស់ព្រះពុទ្ធសាសនា បានឃើញគុណតម្លៃនៃព្រះធម៌ កាលបានឃើញគុណតម្លៃនៃព្រះធម៌ហើយ ក៏នាំយកព្រះធម៌មកផ្សព្វផ្សាយ ដល់មាតាបិតាញាតិមិត្តបងប្អូនរបស់ខ្លួន ធ្វើឱ្យសេចក្តីល្អរីកខ្ទរខ្ទាយចេញទៅ ជួយឱ្យមាតាបិតាជាដើមមានចិត្តត្រជាក់មានជីវិតស្រស់ថ្លារុងរឿង ។ បើខ្លួនឯងអាចនាំយកព្រះធម៌ដែលបានសិក្សាហើយ មកបដិបត្តិឱ្យខ្លួនឯងជាបព្វជិតល្អផង ជួយណែនាំមនុស្សក្នុងសង្គមឱ្យយល់ដឹងបានល្អ បានសុខផង នេះគឺជាការជួយឱ្យមាតាបិតារឹងរឹតតែមានសេចក្តីសុខ សេចក្តីចម្រើន ជាភិយ្យោភាព ។



ការតបស្នងសងគុណមាតាបិតា ខាងដើមជាទីបំផុត នៅត្រង់ទំនុកបម្រុងរាងកាយដោយបច្ច័យ៤ ព្រមទាំងបម្រើការងារសព្វសារពើដែលអាចធ្វើទៅបាន ប៉ុន្តែដែលជាសារៈសំខាន់នោះ គឺធ្វើយ៉ាងណាឱ្យគាត់មាននូវសេចក្តីសុខ ដោយចំពោះធ្វើឱ្យគាត់មាននូវសេចក្តីសុខផ្លូវចិត្ត ។ កាលដែលធ្វើឱ្យមាតាបិតាបាននូវសេចក្តីសុខតាមផ្លូវចិត្តហើយ ក៏ជាការតបស្នងសងគុណដល់មាតាបិតាបានយ៉ាងល្អជាទីបំផុត ព្រោះថា បើកូនធ្វើឱ្យមាតាបិតាក្តៅក្រហាយចិត្ត មានសេចក្តីទុក្ខកង្វល់ ដោយសារការប្រព្រឹត្តមិនល្អរបស់ខ្លួនឯងជាកូននោះ ឈ្មោះថា យើងជាកូនបានបៀតបៀន ទៅលើលោកអ្នកមានគុណដោយពិត តែបើយើងបានធ្វើឱ្យអ្នកមានគុណមានសេចក្តីសុខ មាននូវបីតិប្រកបដោយចិត្តជ្រះថ្លាក្នុងព្រះពុទ្ធសាសនាដូចបានពោលរួចខ្លះហើយ គឺជាការសងគុណដ៏យ៉ាងប្រណីត ។

ការតបស្នងដោយវត្ថុមានអាហារបាយទឹក និងសំពត់ខោអាវជាដើម គឺជារបស់ខាងក្រៅ មិនមែនជា

របស់ដែលមានខ្លឹមសារពិតប្រាកដឡើយ របស់ដែលមានខ្លឹមសារពិតប្រាកដ គឺការនាំមាតាបិតាចូលមករកព្រះធម៌ ឱ្យមាតាបិតាមានសទ្ធាពិតប្រាកដ ឱ្យមានសីល សុតៈ ចាគៈ និង ឱ្យមាតាបិតាជាពុទ្ធបរិស័ទមានបញ្ញា ។ សទ្ធា សីល សុតៈ ចាគៈ និង បញ្ញា ធម៌៥ប្រការនេះ ជារបស់មានតម្លៃ ជាខ្លឹមសារនៃជីវិត គួរកូនប្រុសស្រីខិតខំប្រឹងប្រែងជួយជ្រោមជ្រែងឱ្យមាតាបិតា បានប្រកបទៅដោយធម៌៥ប្រការនេះកុំបីខាន ទោះបីខ្លួនឯងជាកូនបានបួស ឬមិនបានបួសក៏ដោយចុះ ។

កូនដែលបានមកបួសហើយ ត្រូវតាំងចិត្តប្រព្រឹត្តឱ្យបានល្អជាទីបំផុត ជាប្រយោជន៍ដល់ខ្លួនឯងជាអ្នកបួសផង ជាប្រយោជន៍ដល់អ្នកដទៃ មានមាតាបិតាជាដើមផង ។

មាតាបិតានឹករលឹកដល់លោកកូនហើយ ក៏កើតបីតិមានសេចក្តីសុខ ពេលនឹកដល់លោកកូនបួសជាព្រះសង្ឃនៅវត្ត ក៏នឹកដល់ទៅថា លោកកូនតាំងចិត្តសិក្សាព្រះធម៌ព្រះវិន័យ មានជីវិតរស់នៅក្នុងសីល និងកល្យាណធម៌ ។



ពេលនឹករលឹកដល់លោកកូនហើយ ក៏នឹករលឹកដល់ព្រះពុទ្ធសាសនា នឹកឃើញវត្ត នឹកឃើញព្រះសង្ឃច្រើនអង្គ នឹកឃើញព្រះចេតិយ នឹកឃើញព្រះពោធិព្រឹក្ស នឹកឃើញសូត្រធម៌ នឹកឃើញស្តាប់ធម៌ ។ល។ អនុស្សតិក៏រមែងចម្រើនដល់មាតាបិតា ។ ពេលឃើញកូនស្លៀកដណ្តប់សំពត់ពណ៌លឿង សង្រួមត្រឹមត្រូវ និមន្តមកបិណ្ឌបាត ហឫទ័យរបស់មាតាបិតាពោរពេញទៅដោយបីតិប្រកបព្រមទៅដោយសេចក្តីតាំងចិត្ត ដើម្បីតម្កល់ខ្លួនឱ្យជាញោមប្រុសស្រីដ៏ល្អ ។ ឃើញកូនពេលណា នឹករលឹកដល់កូនពេលណា ក៏មានសេចក្តីសុខ និង ជ្រះថ្លាពេលនោះ ។ នេះឯងជាទិសដៅប្រការទី៣នៃការបួស គឺការតបស្នងដល់ព្រះគុណរបស់មាតាបិតា ។

បើបព្វជិតទាំងឡាយ ប្រព្រឹត្តបដិបត្តិល្អ តាំងចិត្តរៀន ហ្វឹកហាត់អប់រំក្នុងព្រះធម៌វិន័យ ចម្រើនក្នុងសីល សមាធិ បញ្ញា ក៏សម្រេចបាននូវខ្លឹមសារនៃការបួស គឺដើម្បីរួចផុតចាកទុក្ខ ហើយក៏បានសម្រេចនៅក្នុងទិសដៅ



Document Produced by deskPDF Unregistered :: http://www.docudesk.com

៣ប្រការទៀត ដែលមានផលដល់ព្រះពុទ្ធសាសនាផង មានផលដល់សង្គមជាតិផង មានផលដល់មាតាបិតាផង ដូច្នេះ សូមកុលបុត្រទាំងឡាយ ពិចារណាតាមការគួរ ។

## ព្រះគាថាធម្មបទ

ទុប្បព្វជ្ជំ ទុរភិរមំ ទុរាវាសា ឃរា ទុខា
ទុក្ខោ សមានសំវាសោ ទុក្ខានុបតិតទ្ធគូ
តស្មា ន ចទ្ធគូ សិយា ន ច ទុក្ខានុបតិតោ សិយា។

ការបួសជាការក្រលំបាក (គឺមិនងាយចេញមកបួសថ្វាយជីវិតចំពោះព្រះសាសនា) បួសហើយកាលណា មានការត្រេកអរនឹងបដិបត្តិតាមធម៌វិន័យ ក៏ជាការកម្រណាស់, ផ្ទះសម្បែងដែលរក្សាមិនបានល្អ នាំឱ្យកើតទុក្ខ (គឺការគ្រប់គ្រងផ្ទះមិនងាយនឹងបំពេញកិច្ចការឱ្យពេញឡើយ ដូចពាងផ្ទះ ឬដូចជាមហាសមុទ្រ), ការនៅរួមជាមួយមនុស្សស្មើគ្នាជាទុក្ខ (ទុក្ខព្រោះការប្រជែងគ្នា «អ្នកឯងជាស្អី



យើងជាស្អី» ការមិនស្តាប់គ្នាទៅវិញទៅមក ការមិនគោរពគ្នា ក៏ជាអ្នកខ្វល់ខ្វាយក្នុងអធិករណ៍ គឺជម្លោះ), អ្នកដើរផ្លូវឆ្ងាយគឺវដ្តៈជាអ្នកមានទុក្ខជាប់តាម ព្រោះហេតុដូច្នោះ បុគ្គលមិនគប្បីជាអ្នកដើរផ្លូវឆ្ងាយ និង មិនគប្បីជាអ្នកមានទុក្ខជាប់តាមឡើយ ។

❋ព្រះគាថាធម្មបទនេះ ព្រះអង្គទ្រង់ប្រារព្ធចំពោះភិក្ខុវជ្ជីបុត្រ កាលដែលព្រះអង្គគង់ប្រថាប់នៅនាមហាវ័ន ជិតក្រុងវេសាលី ។

### ចប់ខ្លឹមសារនៃការបួស

**ទីឃោ ពាលានំ សំសារោ សទ្ធម្មំ អវិជានតំ**
សង្សារវដ្តវែងឆ្ងាយ សម្រាប់បុគ្គលពាលទាំងឡាយ
ដែលមិនមានការដឹងច្បាស់នូវធម៌របស់សប្បុរស ។



Document Produced by deskPDF Unregistered :: http://www.docudesk.com

Document Produced by deskPDF Unregistered :: http://www.docudesk.com

# ពាក្យប្រារព្ធ

សៀវភៅ **ខ្លឹមសារគួរយល់ដឹង** នេះ មាន៤ខ្លឹមសារ ជាជំនួយដល់ការយល់ដឹងរបស់ អ្នកអាន និង អ្នកបានស្ដាប់ ។

សៀវភៅនេះ ខ្ញុំព្រះករុណា ខ្ញុំបាទ មាន បំណងដើម្បីឱ្យបានជាធម្មទាន ក្នុងថ្ងៃវិសាខបូជា ព.ស ២៥៤៥ ដូច្នេះ ទើបនៅក្នុងសៀវភៅនេះ មានបកស្រាយអំពី **ខ្លឹមសារនៃសំវេជនីយដ្ឋាន ៤កន្លែង** គឺ៣កន្លែងទាក់ទងនឹងវិសាខបូជា និង ១កន្លែងទៀត ទាក់ទងនឹងអាសាឡ្ហបូជា ។

ការបូជាដល់ព្រះរតនត្រ័យ សូម្បីមាននូវ សទ្ធាហើយ ប៉ុន្តែបើខ្វះបញ្ញា ក៏ជាការទន់ខ្សោយ ពោលគឺការបូជានោះ មិនមាននូវកម្លាំងមាំមួន ឡើយ ដូច្នេះត្រូវស្វែងយល់ពីខ្លឹមសារធម៌ ដែល ជាឧបការៈនាំឱ្យកើតបញ្ញាដល់ពុទ្ធបរិស័ទ ។



បើពុទ្ធបរិស័ទដល់ព្រមដោយសទ្ធានិងបញ្ញា ហើយ ការបូជាដល់ព្រះរតនត្រ័យ រមែងសម្រេច ផលប្រមាណមិនបានឡើយ សូម្បីក្នុងពេលដែល កំពុងតែបូជានោះ សភាពនៃចិត្តក៏បរិសុទ្ធ ព្រោះ ប្រកបដោយ បីតិ បស្សទ្ធិ និង សមាធិ ដែលជាខ្លឹមសារនៃសេចក្ដីសុខ ។

ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងនៅក្នុងធម្មបទ ពុទ្ធវគ្គ រឿងកស្សបទសពលសុវណ្ណចេតិយ ថា :

អ្នកណាៗ ក៏មិនអាចរាប់នូវបុណ្យ របស់ អ្នកដែលបូជាដល់បុគ្គលដែលគួរបូជា គឺព្រះពុទ្ធ និង សាវ័ករបស់ព្រះពុទ្ធទាំងឡាយផង ជាអ្នក កន្លងនូវបបញ្ចធម៌ (ធម៌ជាគ្រឿងយឺតយូរ បាន ដល់តណ្ហា មានះ ទិដ្ឋិ)បានហើយ ជាអ្នកមាន សេចក្ដីសោកខ្សឹកខ្សួលអស់ហើយ សូម្បីបុគ្គល ដែលគួរបូជាទាំងនោះ ជាអ្នកមិនមានភ័យអំពី

Document Produced by deskPDF Unregistered :: http://www.docudesk.com

ទីណា បានបរិនិព្វានទៅហើយក៏ដោយ ក៏នៅតែមិនមានអ្នកណាៗ អាចរាប់បុណ្យរបស់អ្នកបូជានោះបានឡើយ (ព្រោះវិបាកមិនមានទីបំផុត) ។

**សក្កទេវរាជ បានពោលទុកនៅក្នុង វិមានវត្ថុថា :**

កាលព្រះសម្មាសម្ពុទ្ធជាដើម ទ្រង់គង់ព្រះជន្មនៅក្តី បរិនិព្វានទៅហើយក្តី កាលបើចិត្ត (របស់អ្នកបូជា)ស្មើគ្នា ផលក៏រមែងស្មើគ្នា ។ ព្រោះហេតុសេចក្តីជ្រះថ្លានៃចិត្ត សត្វទាំងឡាយរមែងទៅកាន់សុគតិភព ដោយប្រការដូចនេះ ។

**ជីវិតដែលគ្រប់គ្រងដោយព្រះធម៌ ជាជីវិតសុខស្ងប់**

គួរបែងចែកពេលវេលាមួយចំណែកឱ្យបានប្រាកដ សំរាប់សិក្សា និង បដិបត្តិនូវព្រះធម៌ ព្រោះមនុស្សយើងមានទាំងរាងកាយ មានទាំងវិញ្ញាណ។ មាសប្រាក់កែវកងវត្ថុសម្ភារៈជាគ្រឿងសម្រាប់រក្សារូបកាយ តែព្រះធម៌ជាគ្រឿងសម្រាប់



រក្សានូវវិញ្ញាណ បើវិញ្ញាណខ្វះព្រះធម៌ហើយ វិញ្ញាណមិនអាចស្វែងរកបាននូវសេចក្តីសុខ ដ៏ពិតប្រាកដឡើយ ។

មានតែព្រះធម៌ជាធម្មរតនៈម្យ៉ាងគត់ ដែលវិញ្ញាណបានអាស្រ័យហើយ មានការស្បើយទុក្ខរួចផុតអំពីកង្វល់វឹកវរ និង សម្រេចបាននូវសេចក្តីសុខស្ងប់ដ៏ពិតប្រាកដ ។

សូមឱ្យពុទ្ធបរិស័ទចម្រើនទៅដោយការយល់ដឹង ព្រោះអាស្រ័យបានអាន និង បានស្តាប់នូវខ្លឹមសារធម៌ក្នុងសៀវភៅនេះ ។

**រាជធានីភ្នំពេញ,ថ្ងៃ ១៥កើត ខែពិសាខ ព.ស ២៥៤៥**

**ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត សាវង្ស**
**តំណាងពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន**

Document Produced by deskPDF Unregistered :: http://www.docudesk.com

## នាមពុទ្ធបរិស័ទអ្នកមានឧបការៈ

## ក្នុងការខារធម្មទាន

១.ឧបាសក សិរ៉ង វណ្ណ  ២.ឧបាសក យន្ត សួន

៣.ឧបាសក គួង លាងផេង  ៤.ឧបាសក មួង យេន

៥.ឧបាសក រស់ សូផាត  ៦.ឧបាសក គុយ សុធន

៧.នាង ជា សុណារី  ៨.នាង ឃុន សូទីម៉ា

**សព្វទានំ ធម្មទានំ ជិនាតិ**

ធម្មទានឈ្នះអស់ទានទាំងពួង

***បោះពុម្ព ២០.០០០ ក្បាល***

***សម្រាប់ជាធម្មទាន***



## ស្ថានីយវិទ្យុ ផ្សព្វផ្សាយព្រះធម៌

## ព្រះពុទ្ធសាសនា

## ដោយសហគមន៍ធម្មទាន នៃពុទ្ធបរិស័ទ

| ខេត្ត-ក្រុង | វេលាផ្សាយ | ស្ថានីយវិទ្យុ |
|---|---|---|
| រាជធានីភ្នំពេញ | -05h00 mn<br>-19h00 mn<br>-19h30 mn<br>-19h30 mn<br>-20h00 mn<br>-20h30 mn | -FM 99 MHz<br>-AM 918 MHz<br>-FM 95 MHz<br>-FM 97 MHz<br>-FM 98 MHz<br>-FM 107 MHz |
| ក្រុងព្រះសីហនុ | -06h30 mn<br>-13h30 mn | -FM 92 MHz |
| ខេត្តបាត់ដំបង | -06h00 mn<br>-17h30 mn | -FM 103.2MHz<br>-FM 91 MHz |
| ក្រុងប៉ៃលិន | -18h00 mn | -FM 90 MHz |
| ខេត្តសៀមរាប | -18h30 mn | -FM 100.5MHz |

**សុខា សទ្ធម្មទេសនា**

កិរិយាសម្តែងនូវព្រះសទ្ធម្ម នាំមកនូវសេចក្តីសុខ

Document Produced by deskPDF Unregistered :: http://www.docudesk.com

# សៀវភៅដែលរៀបរៀងដោយ

## ខ្ញុំព្រះករុណា ខ្ញុំបាទ

## ✍ ប៊ុត_សាវង្ស ✍

១_ខ្លឹមសារគួរយល់ដឹង

២_ជំនួយសតិភាគ ១ ដល់ភាគ៦

៣_មនុស្សជាមួយនឹងការងារ

៤_សិក្ខាបទមនុស្សល្អ

៥_ពរ៤ប្រការ

៦_ព្រះពុទ្ធភាសិត ៤៣គាថា

**ហនន្តិ ភោគា ទុម្មេធំ នោ ច បារគវេសិនោ**

ភោគៈទាំងឡាយ តែងសម្លាប់នូវបុគ្គលល្ងង់ខ្លៅ តែមិនសម្លាប់នូវបុគ្គលដែលស្វែងរកត្រើយ គឺ ព្រះនិព្វានឡើយ ។



រូប

## សម្តែងបឋមទេសនា,ធម្មចក្កប្បវត្តនសូត្រ ប្រោសបញ្ចវគ្គីយ៍ឱ្យស្គាល់ផ្លូវត្រូវគឺផ្លូវកណ្តាល

ថ្ងៃដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងនូវព្រះធម៌ «បឋមទេសនា» គឺថ្ងៃ១៥កើត ខែអាសាឍ ក្រោយអំពីការត្រាស់ដឹងរបស់ព្រះអង្គរួចមកបាន២ខែ ។

ថ្ងៃ១៥កើត ពេញបូណ៌មី ខែអាសាឍនេះ គឺជាថ្ងៃកំណើតព្រះធម៌ផង ជាថ្ងៃកំណើតព្រះសង្ឃផង ដូច្នេះ កាលបើដល់ថ្ងៃ១៥កើត ខែអាសាឍ មុនចូលវស្សា១ថ្ងៃ (ចូលវស្សាថ្ងៃ១រោចខែអាសាឍ) គួរពុទ្ធបរិស័ទធ្វើនូវ **អាសាឡ្ហបូជា** កុំបីខាន ។

បឋមទេសនាដែលព្រះអង្គទ្រង់សម្តែង បានដល់ធម៌បដិសេធនូវផ្លូវបដិបត្តិ ដែលអ្នកបួសក្នុងសម័យនោះនិយមប្រព្រឹត្ត គឺការធ្វើខ្លួនឱ្យលំបាកឥតប្រយោជន៍ និងធម៌បដិសេធនូវផ្លូវម្យ៉ាងទៀត គឺការបណ្តោយជីវិតតាមកាមតណ្ហា ផ្លូវទាំងពីរនេះទ្រង់បដិសេធថា មិនមែនជាផ្លូវនៃការត្រាស់ដឹងឡើយ ។

ព្រះអង្គទ្រង់បានសម្តែងប្រាប់នូវផ្លូវកណ្តាល ដែលហៅថា **«មជ្ឈិមាបដិបទា»** ថាជាផ្លូវបដិបត្តិដ៏ល្អប្រពៃ ជាផ្លូវប្រកបដោយអរិយមគ្គអង្គ៨ ដែលពោលដោយសង្ខេបគឺ សីល សមាធិ បញ្ញា ។